# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ណុប ហាត I03664

## សម្ភាសជាមួយ ណុប ហាត ជាម្ចាស់ប្រវត្តិរូប

## នៅភូមិស្រង់ ឃុំចំណារលើ ស្រុកស្ទោង កំពង់ធំ

## ថ្ងៃទី២០ ខែមករា ២០០៣

## សម្ភាសដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

(ផ្នែក៖ ថតអត់ជាប់)

……

ណុបៈ គេយាមណា៎ កន្លែងថាមេគេ កន្លែងទាហានគេនៅមុន… ខ្មែរក្រហមនៅមុនណា៎ យើងទៅពីនេះខ្លួនទទេទេ ។

ឃិនៈ បន្ទាយគេ?

ណុបៈ បន្ទាយគេហ្នា ដែលចូលទៅ ។

ឃិនៈ ហើយកាលណោះបានបើក?

ណុបៈ បាទ! ហើយបើក ទៅបើកអត់មានឲ្យថា យើងនឹងមានទាំងអស់គ្នាទេ ។

ដារ៉ាៈ រដូវឆ្នាំនៅពូ ពេលដែលពូទៅដល់កំពង់ថ្ម បុក៏ទៅព្រៃទទឹង?

ណុបៈ ទាន់រដូវឆ្នាំទេ ។

ដារ៉ាៈ ក្នុងខែណា?

ណុបៈ ចុះបើខ្ញុំទៅពីខែប្រាំមួយទាន់អី ទឹមទៅពីនេះដើរទៅពីរបីថ្ងៃហ្នុះ មិនទាន់រដូវទេ ។

ដារ៉ាៈ ចឹងទៅដល់ព្រៃទទឹងហ្នឹងមានចែកជាកង មានផ្តល់ជាអាវុធទេ?

ណុបៈ ដល់ផ្តល់ទទឹងអត់ នៅតែអត់ ។

ដារ៉ាៈ នៅតែអត់ទេ?

ណុបៈ បាទ!

ដារ៉ាៈ ក្រោយមកទៅកន្លែងណា?

ណុបៈ ទៅកន្លែងបន្ទាយគេ ។ បន្ទាយខ្មែរក្រហម ។

ដារ៉ាៈ របស់ខ្មែរក្រហម?

ណុប៖ បាទ! របស់ខ្មែរក្រហម ។ នៅដូចថាខ្មែរត្រៀមគេណា៎ ដូចថាយើងនៅជិតដាំបាយនេះណា៎ ។

ដារ៉ា៖ បាទ!

ណុប៖ ហើយដែលថាខ្មែរត្រៀមគេនៅឆ្ងាយៗ ដូចភូមិចម្រើន នៅអីណាទីងដារណ្តៅបុគ្គលរណ្តៅអីគេណឹងណា៎ ត្រង់សេណា៎ ។ ហើយយើងទៅកន្លែងនេះ បានមានកាំភ្លើង ។ នៅកន្លែងនេះណា៎ នៅកន្លែងបាយនេះណា៎មានកាំភ្លើង ។ បាយដែលយើងយកទៅឲ្យគេនៅមុខណា៎

ដារ៉ា៖ នៅកន្លែងបាយទឹកអីហ្នឹង?

ណុប៖ បាទ!បាយទឹក ។ បានមានកាំភ្លើង មានគេប្រគល់កាំភ្លើងអីឲ្យហើយ ។

ដារ៉ា៖ អញ្ចឹងអ្នកដែលទៅជាមួយពូពីភូមិទៅ
ដូចថាពេលដែលដើរទៅរហូតដល់កន្លែងបាយដែលពូនិយាយហ្នឹង
ដូចថាមានស្លាប់មានអីទេ?

ណុប៖ អត់មានទេ ។

ដារ៉ា៖ អត់មានទេ ។

ណុប៖ ចុះបាយទឹកអីយ៉ាងម៉េចដែរ? ពេលដើរហ្នឹង?

ដារ៉ា៖ បាយទឹកអី ដាំខ្លួនឯងតាណាក់ៗ ដាំអញ្ចោះ ដូចថាមេខ្យល់ដើរទៅដល់ ត្រឹមណាមាន ទឹកមានអី គេឲ្យយើងដាំស៊ីត្រង់ហ្នុះឯង ។

ឃិន៖ ឆ្នាំងចានអីយកឯណា?

ណុប៖ បាទ!ម៉ាស្ពាយទៅម៉ាខ្ទងទៅអង្ករទៅសាច់ចេញពីផ្ទះនេះទៅគេបើកឲ្យទៅស្រេចៗ ។

ឃិន៖ ណាស្ពាយឆ្នាំងៗ ណាស្ពាយអង្ករៗទៅ

ណុប៖ បាទ!ណាត្រីងៀតណាអង្ករៗទៅ ។ ដើរទាំងយប់ដើរទាំងថ្ងៃទៅ ។ មិនដើរតែថ្ងៃ ទេណាយប់ក៏ដើរដែរ ដើរផងលុយដេកចាប់ដៃគ្នាចូលព្រៃចូលផ្សេងហ្ន ។

ឃិន៖ កាលទៅៗជាមួយពីណា?

ដារ៉ា៖ ពូមានស្រីទៅជាមួយដែរ?

ណុប៖ អត់មានសោះ ។ សុទ្ធតែប្រុសទាំងអស់ ។

ដារ៉ា៖ មានស្គាល់ឈ្មោះពីណាខ្លះ ជាមិត្តភក្តិនៅក្នុងភូមិជាមួយគ្នា ទៅជាមួយពូហ្នឹង?

ណុប៖ ខ្វះអីនៅនេះម៉ាគំនរ ។

ដារ៉ាៈ នៅរស់?

ណុបៈ បាទនៅរស់ពីរបីនាក់ដែរ ។ មកវិញអ្នកខ្លះអស់ខ្លួន អស់ដៃអីអស់អី

ដារ៉ាៈ ឈ្មោះអីខ្លះទៅ?

ណុបៈ ង៉ែត ជា មួយ

ដារ៉ាៈ បាទ!

ណុបៈ ហើយអាអីលេងភ្លេង ។ អាពៀក ។ យៀវ ពៀក ។

ដារ៉ាៈ ទៅជាមួយពូ?

ណុបៈ ទៅជាមួយខ្ញុំនោះអ្ហែង

ដារ៉ាៈ តែនៅរស់បានមានជីវិត រាល់ថ្ងៃ?

ណុបៈ នៅ មកវិញ

ឃិនៈ នៅក្នុងភូមិហ្នឹង

ណុបៈ បាទមកនៅក្នុងភូមិវិញហើយ ។

ដារ៉ាៈ ដល់ពេលចូលដល់ភ្នំពេញ ឬក៏ទៅវ៉ៃនៅក្នុងកងជាមួយ?

ណុបៈ បាទ! នៅ នៅជិតគ្នានោះឯង ។ ដូចថាកងពលវាតែមួយអ្ហាស ។

ដារ៉ាៈ បាទ! ចឹងពូ កាលពូចេញពីភូមិទៅ ទៅដល់កន្លែងថា កន្លែងដាំបាយ ហើយមាន កាំភ្លើង ហ្នឹងណា៎ កន្លែងហ្នឹងនៅក្នុងភូមិអី ឃុំអី?

ណុបៈ អត់មាន ព្រៃហ្នុង?

ដារ៉ាៈ ព្រៃតែនៅក្នុងទឹកដីខេត្តអី

ណុបៈ ខាងលង្វែក

ដារ៉ាៈ លង្វែក កំពង់ឆ្នាំង?

ណុបៈ ខាងកំពង់ឆ្នាំង លង្វែក ។ ព្រៃលង្វែកហ្នុងណឹង ។ ខាងលិចលង្វែក ។

ដារ៉ាៈ ពូទៅដល់ហ្នឹង...

ណុបៈ ខាងសាលាលេខ៥

ដារ៉ាៈ ពូគេឲ្យធ្វើអី?

ណុបៈ ទេ អត់ទាន់មានថាឲ្យធ្វើអីទេ ។ គេឲ្យទៅនៅជាមួយនឹងគេហ្នឹង ។ ដល់ទៅដូច ថា គេត្រូវមានគេឲ្យហាត់ណឹះ ព្រឹកៗឡើងគេឲ្យយើងហាត់ទៅ ឬល្ងាចអី ។ គេហាត់លូន ហាត់ ក្រាប ហាត់រត់ ហាត់អីទៅណា៎ ។

យិនៈ មានកន្លែងហាត់រៀនដែរ?

ណុបៈ បាទ! នៅកន្លែងហ្នឹង កន្លែងយោធាហាត់រៀន ។

យិនៈ ប៉ុនសុទ្ធតែព្រៃ?

ណុបៈ បាទ! មានកន្លែងវាល មានកន្លែងព្រៃដូចយើង មានណា... ចូលព្រៃម្ដងៗ ។

ដារ៉ាៈ បង្ហាត់ណឹងក៏ជា អ្នកណាបង្ហាត់? ទាហាននៅហ្នឹង?

ណុបៈ ទាហាន

ដារ៉ាៈ មានគាំងវៀតណាមមកបង្ហាត់ដែរ?

ណុបៈ អត់ទេ ។

ដារ៉ាៈ អត់ទេ? មានតែខ្មែរ ។

ណុបៈ មានតែខ្មែរក្រហមសុទ្ធតែម្ដង ។

ដារ៉ាៈ ខ្មែរក្រហមសុទ្ធ?

ណុបៈ ខ្មែរក្រហមហ្នឹង

ដារ៉ាៈ ពូនៅហ្នឹងបានប៉ុន្មាន?

ណុបៈ ខ្ញុំនៅ បានប៉ុន្មានខែទេ បីបួនប្រាំខែដឹង ។ នៅយូរដែលបន្ទាយលង្វែក ខ្ញុំនៅ ប៉ុនតែវើមិនដាច់ទេ នៅក្នុងលង្វែកនោះណា៎ គ្រាន់តែនៅក្នុងព្រៃវើតិចតួចៗ ។

ដារ៉ាៈ អត់មានចូលក្នុងភូមិបានទេ? អត់មានចូលភូមិកៀកទេ?

ណុបៈ អត់ចូលបានទេ ។ ចូលនឹងបន្ទាយ អត់វាយបានទេ ។

យិនៈ អីចឹងបន្ទាយលង្វែកនៅខាងទាហានលន់ ណុលគ្រប់គ្រងទេ ។

ណុបៈ នៅតែគ្រប់គ្រងទេ ។

យិនៈ ហើយខ្មែរក្រហមនៅតែក្នុងព្រៃ?

ណុបៈ នៅក្នុងព្រៃ ។ ចឹងបានជាខ្ញុំមិនស្គាល់នៅក្នុងវាព្រៃនោះទេ ។ លង្វែកនៅតែទាហានរហូតទាល់តែយើងជិតអាណេះដាច់បានលង្វែកដាច់ដែលលេចជាទ្រង់ទ្រាយអញ្ចេះទៅណា ។

ដារ៉ាៈ ចុះនៅកន្លែងហាត់កន្លែងអីហ្នឹង ពូស្គាល់អ្នកណាជាខ្មែរក្រហមទទួលខុសត្រូវនៅកន្លែងហ្នឹង

ណុបៈ អេមិនដឹងទេ មេគេ មិនសូវបានស្គាល់ឈ្មោះគេ គេម៉ោវាអត់ស្គាល់ ។

ដារ៉ាៈ ទោះបីជាពូអត់ស្គាល់ជារូបរាងមនុស្សប៉ុន្តែពូធ្លាប់ឮឈ្មោះទេ? ថាឈ្មោះអ្នកណាដែលជាអ្នកគ្រប់គ្រងកន្លែងបាយ? កន្លែងហាត់អីនៅលង្វែក?

ណុបៈ នៅលង្វែកអត់ស្គាល់ទេ ។ ព្រោះនៅកន្លែងនោះគេគ្រប់គ្រងមែន ប៉ុន្តែខ្ញុំទៅសាថ្មីណ៎ា ប៉ុនមិនសូវការចាប់អារម្មណ៍នឹងគេទេ បាននឹងមានបាយអី បាយបេកយើងហ្នឹង អង្ករបេកយើងហ្នឹងអង្ករបេកតើ ។ ដាំយកអង្ករបេកទៅបើកឃ្លាំងទៅ គេឲ្យទៅយក អាកន្លែងសេដ្ឋកិច្ចដែលគេថាទៅយកឃ្លាំងណាក៏ទៅយកអង្ករបេកបាទគេផ្ញើចិតនោះណា ។ ទាហានទំពារអានោះតើ វាមិនដាច់ពេលហងនៅកន្លែងនោះ ។ បើធ្វើម៉េច យើងឆ្លងម៉េច រួច បើទឹកទន្លេហ្នុះ ឆ្លងរួចអ៎ូទឹកទន្លេ ។

ដារ៉ាៈ ម៉េចមានកម្លាំង និយាយមែនទែនម៉េចមានកម្លាំងវ៉ឺ?

ណុបៈ ទេ ចុះបើមាន ឬគ្មានបើគេដូរបេះណ៎ា ដូចថាម៉ាក្រុមដប់នាក់អីបេះណ៎ា ហើយ ណោះទៅ វ៉ឺតិចតួច វ៉ឺម៉ាព្រះមិនប្រហែលមកអង្គុយនេះផង ដើរវ៉ឺឈ្លបតិចៗ បាញ់ម៉ាគ្រាប់២គ្រាប់ បើអាណាមិនបាញ់ក៏អត់មកវិញទៅ ។ ហើយបើទាហាន នោះមិនដឹងនៅណានៅក្បែរភូមិណោះហើយបើយើងនៅណោះអីដើរៗទៅក៏ទៅបាញ់ ណោះប្រូង ក៏ដើរ មកវិញទៅ ។

ឃិនៈ រត់ទៅ?

ណុបៈ បាទ! គេលេងណោះខ្លាំងក៏រត់មក

ដារ៉ាៈ ពូទៅកន្លែងហ្វឹកហាត់នៅកន្លែងលង្វែកនោះបានប៉ុន្មានខែ ប៉ុន្មានឆ្នាំ បានដូរទៅមុខទៀត?

ណុបៈ កាលនោះ ខ្ញុំមកពីលង្វែកនោះបានប្រហែល៥ខែ អ្ហាស ៤ខែ-៥ខែ ។

ដារ៉ាៈ នៅហ្នឹង?

ណុបៈ នៅលង្វែក ។ បានគេបញ្ជូនខ្ញុំមក មកកន្លែងផ្សាល់ទៀត មកអែបភ្នំពេញនេះ មកខាង លិចភ្នំពេញ ។

ដារ៉ាៈ ខាងអី? ខាងខ្វញ ខាងអីហ្នឹង?

ណុបៈ បាទ! ខាងខ្វញ ។

ដារ៉ាៈ ព្រែកប្រា?

ណុបៈ កប់ស្រូវនោះណ៎ា ។គេបញ្ជូនមកនៅនោះឯង ។

ដារ៉ាៈ បញ្ជូនមកនៅក្នុងឆ្នាំណាពូ?

ណុបៈ ឆ្នាំ៧៥ ។

ដារ៉ាៈ ចូលឆ្នាំ៧៥ហើយ?

ណុបៈ បាទ!ចូល៧៥ហើយ ។

ដារ៉ាៈ បញ្ជូនមកហ្នឹងមានដាកង ដាក្រុមអីនៅ?

ណុបៈ មានហើយ ។

ដារ៉ាៈ មានបំពាក់អាវុធអីនៅ?

ណុបៈ ពាក់អាវុធហើយ ។

ដារ៉ាៈ អ៊ីចឹង ។

ណុបៈ ពាក់អាវុធគ្រប់គ្នាហើយ ដែលចូលមកដល់ជិតដល់ណោះ បានមានអាវុធហើយ ។ ដែលនៅអាកៀកនឹងវៃហ្នឹង ។

យិនៈ ម៉េចបានដាចូលមកដល់ខ្ញុំ ខ្ញុំនឹងវាជិតភ្នំពេញហើយណា៎? មានពួកទាហាន លន់ណុល ដែរពេលហ្នឹង? មានដែលវៃប្រយុទ្ធគ្នាដែរ?

ណុបៈ មានអន្តភាពគេចូលវៃ ។

យិនៈ អ៊ីចឹង

ណុបៈ ហើយយើងអ្នកចាំដែលថា ចាំខាងផ្សេងៗ ខាងឆ្អឹងជំនី ខាងអី ។

យិនៈ ទប់?

ណុបៈ ទប់ ។ វាអ៊ីចឹង ។ ដូចថាគេ ហៅថាកងពិសេសៗគេណា៎ ។

ដារ៉ាៈ អូ!

ណុបៈ អាណឹងប្រដេញថាកងពិសេសគេ ចូលឡុកហើយ ។ ហើយយើង ចាំរាំគេពី ក្រោយអីចេះ ទៅណា៎ទទួល ។

ដារ៉ាៈ អ៊ីចឹងពូទៅដល់កន្លែងខ្ញុំកន្លែងអី កន្លែងកប់ស្រូវ ពូចូលក្នុងកងអី ក្រុមអីហើយ?

ណុបៈ ក្រុមភូមិ...។ អូ!ណោះចាំមើលពិបាកណាស់... កាលណោះដឹងភ្លេចអាលេខកងលេខអីហើយ ចាំថាបើលេខកងពល...។

យិនៈ ចាំ?

ណុបៈ ប្រហែល ។ ប្រហែលអីចាំ៣១០ ។

ដារ៉ាៈ កងពល៣១០? អ៊ីចឹងពូដឹងនរណាប្រធានកងពល?

ណុបៈ ប្រធានកងពល កាលមុនតាអឿន ។ ស្គាល់ទេ?

ដារ៉ាៈ បាទ! ព្រោះខ្ញុំធ្លាប់បានសម្ភាសច្រើនដែរ ដែលទាក់ទងនឹងដូចថា អ្នកដែល នៅរស់រានមានជីវិតដូចពូចឹងហីនៅកង តាអឿនអ៊ីចឹង ហើយវៃចូលភ្នំពេញវៃចូលតាម អាខ្ញុំប្រា ដែលពូថាហ្នឹង?

ណុបៈ បាទ!

ដារ៉ាៈ អ៊ីចឹងពូនៅក្នុងដូចថាធម្មតានៅក្នុងរបនាសម្ព័ន្ធយោធា គឺវាមានកងពលចុះពីកងពល មក មានកងវរសេនាធំ ។ ចុះពូនៅក្នុងកងវរសេនាធំអី?

ណុបៈ ថាខ្ញុំភ្លេចហើយ ។

ដារ៉ាៈ អញ្ចឹងវរសេនាតូច?

ណុបៈ អត់ចាំដែល អញ្ចឹងបានថា...វាភ្លេច

ដារ៉ាៈ បន្ទាប់ពីវរសេនាតូច មានកងធំ?

ណុបៈ បាទ! កងធំ ។

ដារ៉ាៈ កងធំ?

ណុបៈ ខ្ញុំអត់ស្គាល់ឈ្មោះទេ ក៏ប៉ុនខ្ញុំក្នុងកងធំទីបី ។

ដារ៉ាៈ កងធំទីបី?

ណុបៈ កងធំទីបី ។

ដារ៉ាៈ ចុះនរណាជាមេកងធំទីបីរបស់ពូ?

ណុបៈ ភ្លេចឈ្មោះហើយ គាត់ហ្នឹងនៅខាងកំពង់ចាម ។

ដារ៉ាៈ រកនឹកមើល?

ណុបៈ ផល? ដឹង?

ឃិនៈ ក្មេងឬចាស់?

ណុបៈ បាទ?

ឃិនៈ ក្មេងក៏ចាស់?

ណុបៈ ក្មេងល្មមដែរ ។

ឃិនៈ មិនទាន់មានប្រពន្ធទេ?

ណុបៈ កាលណោះនៅទេ ។ នៅទាំងអស់គ្នា ប៉ុន្តែគេរាងស ។ ហីដូចគេជិនាញបេះអក្សរ បេះអីខ្លះ ។

ដារ៉ាៈ បន្ទាប់ពីកងធំម៉ោ ក្រោមទៀតវាមានកងតូច? ហើយពូនៅកងតូចអី?

ណុបៈ អូ! ខ្ញុំភ្លេចអស់បាត់ហើយ ។

ឃិនៈ កងតូច ឬក៏ក្រុម ឬក៏ជាពួក?

ណុបៈ ខ្ញុំវានៅកន្លែងកងតូចហ្នឹងឃើញថារាល់ថ្ងៃប៉ិនថាភ្លេចនិយាយស្មោះត្រង់ទៅទៀតណា៎

ដារ៉ា៖ ចឹងនៅក្នុងកងតូចហ្នឹងមានអ្នកណាជាមេរបស់ពូ?

ណុប៖ ថាខ្ញុំក្មេងឈ្មោះកងតូចដឹងឈ្មោះអីទេ...។

ដារ៉ា៖ ក្រែងលថាពូក្មេងឈ្មោះកងតូចលេខប៉ុន្មានមែន? ប៉ុន្តែឈ្មោះមេ? មេមនុស្ស?

ណុប៖ មេមនុស្សនោះហើយ មេមនុស្សនោះបានថា ខ្ញុំក្មេងទៅទៀតណា៎។ ក្មេងឈ្មោះនោះទៀតទៅណាបានថាខ្ញុំដើរច្រើនពេកបានជាក្មេងអស់អាលឹងគ្នា។ ជួនកាលឃើញ មុខទៅស្គាល់គ្នាទៅ នៅណោះនៅណោះសួរប្រវត្តិគ្នាបានដឹង។

ដារ៉ា៖ បាទ! ចឹងពូនៅក្នុងពេលវ៉ៃចូលខ្ញុំចូលអីហ្នឹងពូវ៉ៃប៉ុន្មានខែ ប៉ុន្មានថ្ងៃទៅបានបែក?

ណុប៖ ខ្ញុំម៉ោមិនបានកន្លះខែផង គេបញ្ជូនម៉ោ គេវ៉ៃយូរហើយ។

ដារ៉ា៖ គេវ៉ៃយូរណាស់ហើយ?

ណុប៖ ខ្ញុំម៉ោដល់គេបែកថ្ងៃនោះឯងបណ្តោយ គេបញ្ជូនខ្ញុំមក ខ្ញុំម៉ោហែៗមក ដឹងថា គេវ៉ៃខ្លាំងណាស់គេបញ្ជូនខ្ញុំមកដល់ខ្ញុំដល់អីខ្ញុំចេះតែដើរម៉ោតាមម៉ោពីក្រោយបណ្តោយ។ រួចណោះទ័ពពួកខ្ញុំដើរមកពីក្រោយ ក៏ចូលមករហូតចូលមកដល់វត្តភ្នំបណ្តោយ។

ដារ៉ា៖ អ៊ីចឹងអត់មានបានវ៉ៃអីទេ?

ណុប៖ អត់មានបានវ៉ៃទេ ពួកខាងខ្ញុំនោះ ដូចថាពួកនៅក្រោយគេណា៎ ពួកនៅក្រោយគេអត់បានវ៉ៃទេ។ ពេលម៉ោវ៉ៃបានឃើញខោអាវទៅជួនមែន ប៉ុនគេអត់ទាន់ដាច់ទេ គេវ៉ៃថយ គេវ៉ៃអង្គិលៗទៅណា៎។ ចេះតែវ៉ៃៗទៅ ខ្ញុំម៉ោពីក្រោយ ពីផ្សារកំពង់ ឆ្នាំងនោះម៉ោ គេឲ្យដើរម៉ោ ម៉ោពីនោះមោជិតណាស់ ទាំងយប់ទាំងថ្ងៃដើរ ទម្រាំទៅដល់គេ...

ដារ៉ា៖ ដល់ពេលដល់ភ្នំពេញបែក?

ណុប៖ ដល់ភ្នំពេញៗចាំមើល ខ្ញុំម៉ោនោះឯងអត់ទាន់បែកទេ។ ខ្ញុំសម្រាកនៅនៅកប់ស្រូវ នៅទំនប់កប់ស្រូវ។ ទំនប់កប់ស្រូវនោះ ព្រឹកឡើង ល្ងៀងៗ គេថាបែកហើយៗ ខ្ញុំដើរចូលទៅគេដែរ។ មកដល់ចូលគេដែរអត់មានពិបាកមានអីទេ ដើរចូលរហូត។

ដារ៉ា៖ ពេលដែលពូដើរចូលទៅក្នុងទីក្រុងភ្នំពេញនោះ ពូឃើញសភាពយ៉ាងម៉េច? ថាមានមនុស្សអីទេ?

ណុប៖ អូ! មានមនុស្សៗអូ! ថាអ៊ូរអរពេញទាំងនោះឯង ចេញចូលដើមិនរួចទេ មនុស្សបែកទឹកបែកដីនៅនោះហើយ។

ដារ៉ា៖ បែកទៅខាងណា?

ណុប៖ មនុស្ស ដើរមិនរួចចូលមិនចុះ។

ដារ៉ាៈ មនុស្សសម្រុកចូលភ្នំពេញវិញ ឬសម្រុកចេញខាងក្រៅ?

ណុបៈ សម្រុកចេញក្រៅ ។

ដារ៉ាៈ ប្រជាជន?

ណុបៈ បាទ! ចេញក្រៅខ្លះ ។ ចុះបើខ្ញុំអត់សូវស្គាល់ដែរមុនដំបូងណា៎ ។ ថាចេញក្រៅចុះ ពីព្រោះគេចូលមុន ហើយគេដេញប្រជាជនណា៎ ។ កាលពីប្រជា ជនគ្នាខ្លាច គ្រាប់ នោះណា៎ ចុះហើយមានចេញជ្រួលច្របូរអាធ្វើដំណើរដូចគ្នាធ្វើដំណើរភ្នំពេញរាល់ថ្ងៃអីចឹងណា៎ ជួនកាលគ្នាមិនទៅរកស៊ីហើយឥឡូវអ្នកភ្នំពេញនោះ ជួនកាលទៅក៏ទៅ អាអ្នកម៉ោ ក៏ម៉ោមិនម៉ោណាទៅណីទេណា៎ ដែលខ្ញុំចូលទៅនោះឯង ។ ហើយខ្លះគេ ដូចថា គេ អ្នកមានអញ្ចេះណាអានេះដូចថាគេចូលពីព្រលឹមណា៎ ប្រកពោធិ៍ចិនតុង ឡានវា កប៉ាល់វាហោះឡើងមិនទាន់អស់ទេ គេមានឡើងកប៉ាល់ហោះ អញ្ចុះហើយវាបុកឲ្យ ឡើងកប៉ាល់ហោះ មនុស្សតែវាអត់ឲ្យទៅ ។ វា១ ពួកខ្មែរក្រហមវាបិទអត់ឲ្យទៅទេ វាបិទ ។ ហើយបើយើងជាខ្មែរក្រហមដែរ គេចិត្តធម៌ល្អ គេជូនទៅ គេជូនទៅឡើង កប៉ាល់ហោះទៅប្រទេសគេ ។

ដារ៉ាៈ គេហៅចេញក្រៅ? ពេលដែលវ៉ៃចូលភ្នំពេញហ្នឹង ចូលដល់មុនដំបូងហ្នឹង នៅតារាងកប៉ាល់ហោះអត់ទាន់មានអស់យន្តហោះទេ?

ណុបៈ នៅ១ ចុះខ្ញុំជូនប្រជាជនម្នាក់ទៅដល់នៅកន្លែងទឹកល្អក់ ។ ខ្ញុំជូនដល់កន្លែងហ្នុង ។

ដារ៉ាៈ ដល់កន្លែងយន្តហោះហ្នឹងហ្នុង?

ណុបៈ ដល់កន្លែងយន្តហោះហ្នុំ ។

ដារ៉ាៈ ចាំឈ្មោះពូមីងហ្នឹងទេ?

ណុបៈ អត់ចាំទេ, មានឪពុក អុសន៎ែ ប្តីគាត់ស្លាប់ហើយ ។ ស្លាប់ឆ្នាំ៧០ ធ្វើទាហាន ។

ដារ៉ាៈ ប្តីគាត់ហ្នឹង?

ណុបៈ បាទ!

ដារ៉ាៈ ម៉េចបានពូដឹងថាប្តីគាត់ស្លាប់?

ណុបៈ ពីព្រោះគាត់ទៅនិយាយដែលខ្ញុំនោះ ខ្ញុំធ្វើខ្មែរក្រហមហើយ ។ ព្រោះគាត់ឃើញខ្ញុំដើរលេងគាត់ហៅខ្ញុំគាត់ហៅកូនៗគាត់នេះខ្ញុំដូចថាគាត់រាប់អានគាត់ទៅ ។ គាត់មានកូនស្រីមួយទេ ន៎ែតែមួយប៉ុណ្ណោះទេ គាត់ឲ្យអាវ អាអាវយើង ដែងអាវទា ហានពីដើមនោះណា

ដារ៉ាៈ បាទ!

ណុបៈ គាត់ឲ្យអាវទាហាន

ដារ៉ាៈ អាវៗដូចអាវប៉ារ៉ា?

ណុបៈ អត់ទេអាវឆ្នូតៗអញ្ចេះទៅណា៎។ រួចខ្ញុំយកអាវ គាត់ចេះហៅកូន គាត់បបួលខ្ញុំទៅ។ ទៅអាមេរិកគាត់ថាចេះ។ ខ្ញុំថាទៅម៉េចរួច។ ខ្ញុំទៅហូបបាយផ្ទះគាត់នោះណា។

ដារ៉ាៈ ពេលដែលចូល?

ណុបៈ ពេលដែលចូលហើយនោះណា។

ដារ៉ាៈ ចូលដល់ភ្នំពេញ?

ណុបៈ ចូលដល់ភ្នំពេញនោះណា។ ដែលចូលពីព្រឹកថ្ងៃប៉ុណ្ណេះៗអីណា។

ដារ៉ាៈ បាទ!

ណុបៈ ពោធិ៍ចិនតុងវានៅទេ នៅកប៉ាល់នៅ។ ដល់នេះទៅខ្ញុំដាច់ចិត្តចុះ ដូចថាជួយធ្វើឲ្យគាត់ចុះជូនទៅៗ គាត់ថាឲ្យខ្ញុំនៅនេះឯងថាមើលផ្ទះមើលអីផង កូនក៏កូនមិន ទៅ។ គាត់ចេះតែ បបួលទៅហើយខ្ញុំអត់ទៅទេ។

យិនៈ បើចោលតែកាំភ្លើងឡើងទៅចប់ហើយ។

ណុបៈ មានអីខ្ញុំជូនទៅដល់ក្លោងទ្វារ ពួកនោះអីគេសួរខ្ញុំថាត្រូវជាម៉េច ខ្ញុំថាបងប្អូនខ្ញុំទេ ចាំខ្ញុំឡើងពេលក្រោយ មានអីគេបើកឲ្យយើងទៅតើ។

យិនៈ ពួកណាសួរ?

ណុបៈ ពួកខ្មែរក្រហមនោះ។

យិនៈ ដល់យើងខ្មែរក្រហមដែរ ពួកវាអត់ថាអីទេណោះ?

ណុបៈ បាទ!វាអត់ថាអីដែរ។ ក៏ខ្ញុំជូន...

ដារ៉ាៈ ជូនទាំងឪពុកទាំងម្តាយហ្នឹង?

ណុបៈ អត់ទេ ឪពុកស្លាប់ហើយ។

ដារ៉ាៈ តែម្តាយនឹងកូន?

ណុបៈ ម្តាយនិងកូនតែពីរនាក់ហ្នឹងទេ។

ដារ៉ាៈ ហើយពូមានស្គាល់ឈ្មោះទេ?

ណុបៈ អត់ស្គាល់ឈ្មោះផង។

ដារ៉ាៈ ម៉េចក៏អត់សួរឈ្មោះ?

ណុបៈ អត់បានសួរ អត់បាននាំ ។ ចុះវាអត់មានបានពេលយូរប៉ុន្មានដែលសួរនាំហ្នឹងម៉ាហូប បាយ ។ សួរទៅប្រញាប់ដែលហ្នឹង គាត់ បើនៅយូរកប៉ាល់ហោះចេញទៅ គាត់មិន ចង់ហូបបាយផង ។ ខ្ញុំចុកបានតែពីរបីមាត់នេះឯង ក៏ដាច់ចិត្តជូនគាត់ចុះ គាត់យំ ល្ហែមល្ហាម ខ្លាំងណាស់នៅមិនកើតអីមិនកើត ។ គាត់បបួលខ្ញុំទៅ កូនអើយ ទម្លាក់កាំភ្លើងហ្នឹងចោលហើយទៅទៅដល់នោះហើយ ខ្ញុំដូចដាច់ចិត្តមិនដាច់ចិត្តទេ ដល់ខ្លោងទ្វារនោះហើយ ឲ្យគាត់ចូល គាត់ឡើងកប៉ាល់ហោះទៅបាត់ ។

ដារ៉ាៈ ឲ្យតែចូលដល់ខ្លោងទ្វាហ្នឹងគឺដឹងតែបានឡើង?

ណុបៈ បាទ! គឺដឹងតែបានឡើងហើយ កប៉ាល់ហោះនៅនោះដែរ ។

ដារ៉ាៈ តើហេតុអីបានជាខ្មែរក្រហមវាអត់នេះចឹងពូ? វាអនុញ្ញាតឲ្យចូល?

ឃិនៈ វាឲ្យឡើងដែរហ្ន៎? វាឲ្យឡើងយន្តហោះ?

ណុបៈ វាអីចេះ វាមិនទាន់បានក្តាប់នរណាជាពិតប្រាកដ ទាំងអស់បាន ។ ឃើញទេ ដល់ចឹងវាបែកជាបក្សជាពួកដូចយើងទៅពីនេះស្គាល់ទៅរាប់អានគ្នាទៅក្នុងព្រៃ ។
ដើររាសពេញតែ វាលហ្នឹង ។ ពេលដល់វានៅយូរបួនប្រាំថ្ងៃបានគេប្រមូលកម្លាំងម៉ោវិញ ។ ណាដើរទៅ ណាៗដើរទៅអត់មានពេលកំណត់ទេ កាលណោះឯង ។

ឃិនៈ ដឹងមេបា មេកើយនៅត្រង់ណាទេ?

ណុបៈ បាទ!អត់ដឹងមេបា កើយនៅណាទេ ។

ឃិនៈ អីចឹងអត់មានណាបញ្ហាអីទេ?

ណុបៈ អត់មានណាបញ្ហាអីទេ ។

ឃិនៈ ចឹងបានអត់មានដែនការទប់ទល់?

ណុបៈ ដើរសេរី

ឃិនៈ រួចចុះកប៉ាល់ហោះដែលចុះត្រៀមយកហ្នឹង កប៉ាល់ហោះច្រើនទេ?

ណុបៈ កប៉ាល់ហោះ ដែលខ្ញុំចូលនោះ កប៉ាល់នៅប្រហែលពីរទៀត ។

ឃិនៈ តែពីរទេ?

ណុបៈ ហើយគេឡើងទៅហែៗទៅមុនហើយ ។

ដារ៉ាៈ អាកន្ទុំរុយយើងហ្នឹង?

ណុបៈ អាកន្ទុំរុយយើងហ្នឹង ។

ឃិនៈ នៅតែពីរទេ?

ណុបៈ បាទ! នៅពីរ ។

ឃិនៈ ហើយអ្នកបើកហ្នឹងអាមេរិកាំង ឬខ្មែរ?

ណុបៈ អត់ដឹងដែរ ។

ឃិនៈ អូ! មិនឃើញទេ ។

ដារ៉ាៈ ពូអត់បានចូលទៅក្នុងទេ?

ណុបៈ អត់បានចូលទៅក្នុងទេ ។ គ្រាន់សុំគេបញ្ជាបើកនឹងឲ្យចូល ។ ឲ្យម្តាយធម៌ៗខ្ញុំឲ្យទៅ ចុះ ។ រួចទៅគេបើកឲ្យទៅ ។ តែក៏ៗអាអ្នកយាមនោះ ក៏មិនទាមទារពិតប្រាកដ ថាខ្លួនឯងយាម នោះទេ ។

ដារ៉ាៈ អូ! ចឹងទៀត? គ្រាន់ថារូបរាងជាខ្មែរក្រហម?

ណុបៈ បាទ! ជាខ្មែរក្រហមហ្នឹង ។ ចូលលួចអីចូលទៅបាន ។

ឃិនៈ គ្រាន់ទៅបាន?

ណុបៈ ច្រើនណាស់ទៅមនុស្សអូ! កក គ្រាន់អាខ្លះទៅឡើងទាន់មិនទាន់ៗអស់មិនអស់ មិនដឹងទេណា៎ ។

ដារ៉ាៈ បាទ!

ណុបៈ ហីចុះ អឹហ្នឹងដែងខ្ញុំថាទៅហ្នឹងដឹងឡើងទាន់ដែរឬមិនទាន់ក៏អត់ដឹងដែរ ។ ពីព្រោះគាត់ចូលដល់ទៅហើយ ។

ឃិនៈ អញ្ចឹង! អីចុះពួកខ្មែរក្រហមអត់មាននៅកន្លែងយន្តហោះនោះទេ?

ណុបៈ អត់មាននៅក្នុងនោះទេ ។

ឃិនៈ អីចឹងបានជា....

ណុបៈ អត់មានទេនៅក្រៅៗ

ដារ៉ាៈ កូនស្រីគាត់ធំនៅ?

ណុបៈ កូនស្រីគាត់ធំហើយ ។

ដារ៉ាៈ អូ!!

ណុបៈ មែនកូនតូចណា ។ កូនក្រមុំហើយណា៎

ដារ៉ាៈ អីចឹងអឹហ្នឹង?

ណុបៈ នៅរៀន ក្រមុំហើយតែនៅរៀន ។

ដារ៉ាៈ ហីចុះអត់មានសួរឈ្មោះសួរអីគាត់ទេ?

ណុបៈ	អត់ៗ បានសួរអីទាំងអស់ ។ ស្តីក៏មិនបានសួរដែរ ថាវាប្រញាប់អីចេះអ្អែងថា

ដារ៉ាៈ	ពេលមុននឹងចូលភ្នំពេញអី ពូ ដូចថាអត់មានផែនការមានអី ដឹងមុនទេឬយ៉ាងម៉េច ពូ?

ណុបៈ	អត់ដឹងផែនការច្បាស់លាស់ ។ ដឹងថាទៅតែគេ តាមតែគេហ្នឹង គ្មានដឹងថាផែន ការអីនឹង ខ្លួនឯងអីអត់មានគម្រោងអីផែនការ ។

ដារ៉ាៈ	ទៅចេះតែទៅ?

ណុបៈ	ទៅចេះតែទៅៗ ។ យប់ត្រង់ណាដើរត្រង់នោះទៅ គ្នាបីបួននាក់ ។

ដារ៉ាៈ	នៅជាមួយពូហ្នឹងពូស្គាល់ឈ្មោះអ្នកណាដែលជាមិត្តភក្តិរបស់ពូទេ? កាលពេលសម័យទៅជាមួយ?

ណុបៈ	មានតែនៅហ្នឹងស្រុកក្នុងឯងរាល់ថ្ងៃនេះ ។

ដារ៉ាៈ	អញ្ចឹង?

ណុបៈ	ខ្វះបាត់ទៅហើយ ស្លាប់ហើយដឹងមើលទៅវាមិនឃើញ... បានថាវាឈ្មោះអានេះតាចាប ហៅចិបនោះ

ដារ៉ាៈ	តាចាបហៅចិប?

ណុបៈ	បាទ! ក៏បាត់ទៅ បាត់ឈ្មោះដែរ ។ ពៀច ហៅ ផលនោះក៏បាត់ឈ្មោះទៅ ។

ដារ៉ាៈ	អូ! ពេលចូលដល់ភ្នំពេញ ពូនៅជាកងជាក្រុមអីទៀតឬក៏...

ណុបៈ	នៅជាកងជាក្រុមដែរ ។

ដារ៉ាៈ	នៅយ៉ាងម៉េច?

ណុបៈ	នៅជាកងជាក្រុមដដែល ចូលមុនដំបូងដូចខ្ញុំប្រាប់ថាវាបែកបាក់គ្នាណា៎

ដារ៉ាៈ	បាទ!

ណុបៈ	ដល់អីចឹងទៅពួកគេថា នៅប៉ែកខាងលិចខាងកើតនេះនៅឯស្វាយរៀងហ្នឹងណា គេប្រមូលកម្លាំង អត់ឲ្យដើររាត់រាយទេ ។

ដារ៉ាៈ	ខាងស្វាយរៀង?

ណុបៈ	ខាងស្វាយរៀង ខាងព្រៃវែង គេអត់ឲ្យដើរ ។

ដារ៉ាៈ	ចុះពូម៉េចដឹងខាងស្វាយរៀង?

ណុបៈ	គេវៃម្នាងម្នាក់ ។ ទ័ពបូព៌ាគេវៃណោះ យើងវៃទៅពីនេះចាប់ដៃគ្នានៅមុខវាំង ។

ឃិនៈ	កំណត់យកនៅត្រង់ហ្នឹង?

ណុបៈ	កំណត់យកអានោះណា៎

ដាវ៉ា: អ៊ីចឹងដល់ចូលវៃទៅ គ្មាននរណាគ្រប់គ្រងនរណាទៅ អាបូញ៉ាចាប់ផ្ដើមម៉េច?

ណុប: បូញ៉ាគេខណ្ឌផែនដីទីគេនេះ ត្រឹមវាំងហ្នឹងទៅម៉ោណោះផន់គេ គេក្ដាប់ កាលយើងហ្នឹង យើងណោះគេចូលម៉ោបានមានប្រធានមានអីគេម៉ោត្រឹមត្រូវណា៎ យើងនេះ

ដាវ៉ា: ខាងបូញ៉ាហ្នឹង?

ណុប: បាទ! យើងទៅពីនេះវារាត់រាយទេ ៗ ទៅដល់ភ្នំពេញនោះវារាយគ្នាអស់ហើយ អាណា បែកទៅណោះ អាណាបែកទៅណោះទៅ....

ដាវ៉ា: អារាត់អារាយហ្នឹង ពូបើតាមដែលខ្ញុំសម្ភាស់ពូពីមុនៗម៉ោហ្នឹង អ្នកដែលទៅពីខាងកំពង់ធំ នេះ?

ណុប: បាទ!

ដាវ៉ា: ទៅខត្តរហ្នឹងណា? ជាកងមជ្ឈិម កងពលមជ្ឈិម?

ណុប: កងពិសេស ។

ដាវ៉ា: កងពលមជ្ឈិមវាមានកងពលទី១ ទី២ ទី៣?

ណុប: បាទហ្នឹងហើយ ។

ដាវ៉ា: ហើយមានដូចថាអឿនជាអ្នកដឹកនាំទាហានកងពល៣១០របស់ពូ?

ណុប: បាទ!

ដាវ៉ា: ដែលពូនិយាយមិញ? ហើយមានឈ្មោះកុយធួន កុយអី?

ណុប: មាន ។

ដាវ៉ា: ហ្នឹងហើយដឹកនាំទៅអញ្ចឹងហើយ ហេតុអីបានថា ពូថារាត់រាយអត់មានអ្នកដឹកនាំ?

ណុប: មានគេអ្នកដឹកនាំដែរតែដូចថាខាងខ្ញុំ ដូចតាមកងតូច កងធំវាមានការ បែកបាក់ គ្នាចេះ ប៉ុន្ដែថាមេនោះគេក្ដាប់ជាប់ហើយ តែវាក្ដាប់អត់ជិត ។

ដាវ៉ា: បែកបាក់របៀបម៉េចពូនិយាយឲ្យច្បាស់មើល?

ណុប: បែកបាក់ដែលថាចូលភ្នំពេញហ្នឹងឃើញភ្នំពេញភ្នំពេញវាមានភាពអ៊ូរអរច្រើន ណា៎ ។

ដាវ៉ា: អ៊ីចឹងទេ?

ណុប: ភាពអ៊ូអរច្រើនទម្រាំប្រមូលគ្នា រួចឧទាហរណ៍ថាទៅដល់ភ្នាមណា៎ទ័ពគេជូនកាលកម្លាំងមេ គេបានក្ដាប់ជាប់រហូត តាំង ពីកងតូច កងធំម៉ោណា៎ គេជាប់ៗជាមួយយើង ជួនកាល ដូចកងខ្ញុំចឹងណា ឬកង អ្នកណាទៀត ឬដូចថាមានប្រធានកងមានរបួសអីពេលនោះណា វាត្រូវយើងនឹង កើតជាកូនហ្នឹងរាត់រាយខ្វះហើយ ។

ឃិនៈ អូ!ចឹងទេ?

ណុបៈ បាទ! តែមានអាគេនេះ មានគេៗក្តាប់ក៏ដាប់អ៊ីចុះហើយ ។

ឃិនៈ ដាប់ៗ វាបានមេគេវានៅ?

ណុបៈ មេគេវានៅអ៊ីចុះហើយ ។ បើមេគេរៀងសេរី ក៏អាកូនរៀងសេរីដែរ ។ ក៏ខ្ញុំដាប់នៅហ្នឹងនោះហើយ ពួកកងពិសេសនៅនោះដែរនោះ ។ ប៉ុន្តែថាពួកខ្ញុំវាទៅ ពីក្រោយគេវាមានទីមួយទីពីរទីរបី ។វាអ៊ីចេះគេវ៉ៃតាមដំណាក់វា ។ដូចខ្ញុំនោះនៅអាចុងក្រោយគេអាលែតែនៅចុងក្រោយខ្ញុំនៅលផ្នែកបានដាយូរដំណើរចូល ហ្នឹងភ្នំពេញទី១ដូចគេនោះ គេម៉ោទៅ គេវ៉ៃដាច់ក៏ចេះតែម៉ោតាមគេទៅគេថាដាច់ហើយក៏ដាច់តាមគេទៅ ។

ដារ៉ាៈ អ៊ីចឹងពូ ដល់ពេលពូចូលដល់ភ្នំពេញពូនៅខាងណា?

ណុបៈ ខ្ញុំនៅហ្នឹងវត្តភ្នំ ។

ដារ៉ាៈ នៅវត្តភ្នំ?

ណុបៈ បាទ! ពេទ្យធំនោះ ។

ដារ៉ាៈ ចុះមេកើយអី នៅណាអីនៅណី?

ណុបៈ មេកើយ ថាឈ្មោះអីទេ ខ្ញុំមកឈរនៅទួលគោកជំនាន់នោះណា ប៉ុន្តែកងពលដឹងច្បាស់ថាកងពលនៅវត្តភ្នំនោះឯង ។

ដារ៉ាៈ កងទពល៣១០?

ណុបៈ បាទ! កងពល៣១០នៅនោះឯង ។

ដារ៉ាៈ ដល់ពេលអ៊ីចឹងទៅមានសភាពការណ៍អីយ៉ាងម៉េចទៀតទៅ នៅពេលដែលពូនៅហ្នឹង?

ណុបៈ សភាពការណ៍ឯងនៅតាំងពីវត្តភ្នំម៉ោណា៎ គេចាប់ផ្តើ គេមិនទេជំនាន់នោះហ្ន៎ដល់វាស្រុកគេទៅហើយណា៎ គេយកយើងហ្នឹងទៅហាត់វ៉ៃសេរី

ដារ៉ាៈ វ៉ៃអីគេ?

ណុបៈ វ៉ៃសេរីយើងសព្វថ្ងៃហ្នឹង វ៉ៃដាល់នោះណា៎

ដារ៉ាៈ វ៉ៃដាល់?

ណុបៈ វ៉ៃប្រដាល់ហ្នឹង?

ដារ៉ាៈ បាទ! វ៉ៃប្រដាល់ ។

ឃិនៈ ក្បាច់គុន?

ណុបៈ បាទ! ក្បាច់គុន ។ នៅស្អាតនៅអីគេយកក្បាច់គុននោះឯង ។

ដារ៉ាៈ អ្នកណាមកបង្ហាត់ទៅ?

ណុបៈ ន៉ែ ជា សាវាលក់ ហើយហ្នឹង តាមោគ ខាងសៀមរាប ។

ឃិនៈ តាមោគ អ្នកប្រដាល់ដែរអី?

ណុបៈ បាទ! អ្នកប្រដាល់ដែរ ។

ដារ៉ាៈ ហើយហ្នឹង ជា សាវាក់?

ណុបៈ ជា សាវាក់ បាទ! ជា សាវាក់ នៅក្មេង ជាងតាមោគ

ដារ៉ាៈ ប្រដាល់ ហាត់ប្រដាល់នៅវត្តភ្នំហ្នឹង?

ណុបៈ បាទ! ហាត់នៅវត្តភ្នំ ។

ដារ៉ាៈ ពូបានចូលហាត់គេដែរ?

ណុបៈ ខ្ញុំចូលហាត់បានពីរបីខែដែរ រួចក៏ថ្ងោះជើងខ្ញុំឈប់ ។ ខ្ញុំនៅពេទ្យកាល់ម៉ែត្រ ។ ខ្ញុំនៅមុខហ្នឹង នៅមុខនឹងគេធ្វើវាល់ថ្ងៃនៅពេទ្យកាល់ម៉ែត្រ ។

ដារ៉ាៈ បង្ហាត់នៅហ្នឹង?

ណុបៈ គេអត់បង្ហាត់ទេ គេបង្ហាត់នៅវត្តភ្នំ ។ យប់ឡើងគេទៅហាត់នៅហ្នឹង ។

ឃិនៈ រួចចុះម៉េចទៅរក ជា សាវាក់ នោះឃើញ រកត្រង់ណា?

ណុបៈ ដឹងបានទៅរក ជា សាវាក់ ហ្នឹងឃើញ ។

ឃិនៈ យកមកធ្វើគ្រូតែម្ដង?

ណុបៈ យកមកធ្វើគ្រូ ។

ដារ៉ាៈ ហ្នឹងគេក្នុងគោលបំណងអីដែរ?

ណុបៈ គាត់ គោលបំណងគាត់ខាង ប៉ុនខាង វាចេះណា៎ តាមគោលគាត់ដែលខ្ញុំបានដឹងខ្លះ គេរៀនហៅថា គេបញ្ចូលជាស្នូលបក្សហ្នឹងគេណា៎ ។ គេចូលជាបែកកប្ចាគ្នាចេះ ខាងភូមិភាគខត្តរហ្នឹង គេកាន់ខាងអាមេរិកាំង ហើយខាងស្វាយរៀងព្រៃវែងនេះកាន់ខាងយួន ខាងនីរតីនោះគេទៅកាន់ខាងខ្មែរក្រហមណោះ វាខុសគ្នាចេះឯង បក្សវាមានបី

ដារ៉ាៈ កាន់អាមេរិកាំងម៉េចពូ?

ណុបៈ កាន់ដូចថាយើង ពេលនោះទៅយើងរំលំខាងណាមួយណា៎ ដើម្បីពឹងផ្អែកលើអាមេរិកាំង អញ្ចេះ...

ដារ៉ា: ទើបថ្ងៃនេះខ្ញុំបានដួបពូ ពូបានរៀបរាប់ពីបញ្ហារឿងបក្សរឿងពួកអីហ្នឹងណា៎? អ៊ីចឹងខ្ញុំសូមឲ្យពូបញ្ជាក់ម្ដងទៀត ខាងខត្តរ បើសិនជាវ៉ៃឈ្នះទៅ រំលំខាងណាមួយទៅគឺពឹងផ្អែកខាងអាមេរិកាំង ។

ណុប: បាទ!អាមេរិកាំង ។

ដារ៉ា: ហើយខាងបូព៌ា បើសិនជាផ្ដួលរំលំអ្នកណាអីមួយទៅពឹងវៀតណាម ។

ណុប: វៀតណាម ។

ដារ៉ា: ខាងនិរតី បើផ្ដួលរំលំអ្នកមួយទៅ គឺពឹងពាក់ខ្មែរក្រហមនោះឯង?

ណុប: បាទ! ខាងខ្មែរក្រហម ខាងចិន ។

ដារ៉ា: ខាងចិនទៅវិញ?

ណុប: ខាងចិន ។ ខុសគ្នាវាអ៊ីចឹងណា៎

យិន: ហើយពូបានដឹងអាលែង សភាពការណ៍ហ្នឹង កិច្ចការសម្ងាត់ហ្នឹងដឹងពីណា មាននរណាបង្កើតទេ ពូដឹងអារឿងហ្នឹងទេ?

ណុប: មេធំនែ៎ តាអឿនហ្នឹង ។

យិន: តាអឿន ហ្នឹងហ្មង?

ណុប: បាទ! គេបន្លាត់ច្បាស់ចឹងហ្មង ។ តែគ្រាន់តែ ការបន្លាត់ហ្នឹងទាល់តែស្នូលគេ

ដារ៉ា: ទាល់ស្នូល?

ណុប: បាទ! ទាល់តែចូលសម្ព័ន្ធ គេហៅថាសម្ព័ន្ធៗគេនោះណា៎ ។ គេថាចូលសម្ព័ន្ធៗគេជាសាខាបីនាក់ចេះឯង គេប្រជុំប្រាប់បីនាក់នោះឯងក្រៅពីនោះទៀតគេអត់ប្រាប់ទេ ។ ដែលគេថាការណ៍សម្ងាត់ ។

ដារ៉ា: អ៊ីចឹងពូបានចូលសម្ព័ន្ធ?

ណុប: បាទ! ចូលសម្ព័ន្ធនោះគឺការសម្ងាត់នោះទេ ។

យិន: គេហៅសម្ព័ន្ធអី សម្ព័ន្ធយុវកកនោះអ្ហែ៎?

ណុប: បាទ! សម្ព័ន្ធយុវកកនោះហើយ.

យិន: ហ្នឹងគេហៅថាក្រុមស្នូលអីម៉េច?

ណុប: បាទ! ក្រុមស្នូល បើយើងនិយាយសព្វថ្ងៃហៅថាក្រុមស្នូលនោះណា៎ ។ ជាការទុកចិត្ត ។

យិន: ហើយចេញពីនោះទៅបានចេញបក្ខជនត្រៀម ឬបក្ខជនពេញសិទ្ធិ?

ណុប: បាទ! ហ្នឹងបក្ខជនពេញសិទ្ធិ ពេញត្រៀមអីនោះណា៎

យិនៈ ចឹងប្រជុំឲ្យតែពួកហ្នឹងដឹងទេអ៊ីចឹង?

ណុបៈ បាទ!

ដារ៉ាៈ ចឹងពូចូលដល់ឆ្នាំណា បានពូបានចូលសម្ព័ន្ធយុវកក? អ្នកណាខទ្មេសនាមឲ្យពូចូល?

ណុបៈ អ្នកខទ្មេសនាមចូលនៅក្នុងសាលាតែម្តង ខ្ញុំអត់ស្គាល់គេផង ។ គេបញ្ចូលៗតាមស្នូលក្នុងសាលារៀនវត្តហ្នឹង ។

ដារ៉ាៈ បាទ!ចឹងពូនៅឆ្នាំណាបានចូលសម្ព័ន្ធយុវកក?

ណុបៈ ក្នុងឆ្នាំ៧៥ហ្នឹងដែរ ។

ដារ៉ាៈ ឆ្នាំ៧៥?

ណុបៈ បាទ!

ដារ៉ាៈ នៅបែកភ្នំពេញយូរដែរហើយនៅ?

ណុបៈ បែកភ្នំពេញយូរដែលហើយ ។

ដារ៉ាៈ ប្រហែលជាក្នុងខែណា?

ណុបៈ នែ៎ ខ្ញុំដូចប្រឡំខែដែរហើយ ។ ខែ...

យិនៈ ៧៥ ខែ៤ វាត្រូវវៃបែក? ខែមេសា ត្រូវវៃបែកហើយណា៎ អ៊ីចឹងអាចខែ...

ណុបៈ ខ្ញុំ...

ដារ៉ាៈ ហើយបែកភ្នំពេញបានច្រើនថ្ងៃ ច្រើនខែទេ បានចូលបន្ទំពូ?

ណុបៈ ខែ៤ ចាំមើល... ខ្ញុំចូលសម្ព័ន្ធនោះឯង យើងវៃខែបួនហ្នឹងខែខ្មែរខែអី?

ដារ៉ាៈ ខែចេត្រ

ណុបៈ ខែចេត្រ ខ្ញុំដល់ទៅខែពិសាខ ជេស្ឋ ។

ដារ៉ាៈ បានចូលសម្ព័ន្ធ?

ណុបៈ បានចូលសម្ព័ន្ធគេ បានគេឲ្យម៉ោនៅត្រៀមនៅខ្ញូញកប់ស្រូវ ។

ដារ៉ាៈ ម៉ោត្រៀមនៅកន្លែងហ្នឹងវិញ?

ណុបៈ បាទ! ម៉ោនៅហ្នឹងមិនមានត្រៀម អត់មានអាវុធទេ គេដកហើយ ព្រោះគេអញ្ចោះ គេចាប់តាអឿន នឹងទៅសម្លាប់បាត់ហើយ ។ បែកការណ៍ ។

ដារ៉ាៈ អ៊ីចុះពូ នៅពេលដែលពូចូលជាសម្ព័ន្ធយុវកកហ្នឹងគឺ អឿន ហ្នឹងជាអ្នកបង្រៀនរៀនសូត្រ ហើយនៅក្នុងសម្ព័ន្ធយុវកកហ្នឹងម៉ាក្រុម ដូចថាម៉ាកងៗមានតែបីនាក់ទេ ដែលពូនិយាយមិញហ្នឹងណា៎?

ណុបៈ បាទ!

ដារ៉ាៈ ហើយដល់ពេលប្រជុំផែនការអីហ្នឹង នៅលើយុវកកបីនាក់ហ្នឹង?

ណុបៈ បាទ!

ដារ៉ាៈ អីចឹងនៅកន្លែងបក្សផ្សេងៗ ខាងផ្នែកផ្សេងៗទៀតដូនៅបូព៌ាឬក៏នៅនិរតីអីគេមានបីចឹងដែរ?

ណុបៈ បាទ! គេមានមេៗគេខាងណោះ។

ដារ៉ាៈ បីនាក់សម្ព័ន្ធយុវកកអីចឹងដែរ?

ណុបៈ បាទ! មានហើយបានគេបង្កើតកើតនោះ ប៉ុនថាយើងអត់រឿងគេទេណា៎ដឹងរឿងតែខាងយើង។

ដារ៉ាៈ បាទ!ដឹងតែខាងយើង?

ណុបៈ ដឹងតែខាងយើងទេ។

ដារ៉ាៈ ខត្តុរ?

ណុបៈ បាទ!

ដារ៉ាៈ អីចឹងគឺថាមានកិច្ចការផែនការអី សម្ងាត់ឬក៏ផែនការអីត្រូវដាក់ធ្វើយ៉ាងម៉េចៗគឺហៅតែបីនាក់ហ្នឹងទេ? ដែលថាដឹងរឿង

ណុបៈ មានដឹងរឿងសម្ងាត់ការសម្ងាត់។

ដារ៉ាៈ សម្ព័ន្ធយុវកកហ្នឹង

ណុបៈ បាទ! ដូចជារឿងទៅបង្រៀនអីញឹកញាប់ណា៎។ ហៅពួកសម្ព័ន្ធៗហ្នឹងទៅរៀន។

ដារ៉ាៈ ហើយទៅរៀនពូដឹងច្បាស់ចឹងហ្នឹងថាត្រូវផ្តួលរំលំពីរឬយ៉ាងម៉េច?

ណុបៈ គេត្រូវរំលំចឹងអ្អែង គេប្រាប់យើងថាអញ្ចេះឯង។ គេថាផ្តួលរំលំខ្មែរក្រហមចេញទៅ។

ដារ៉ាៈ ដែលវ៉ៃមុនដំបូងហ្នឹង?

ណុបៈ ដែលវ៉ៃមុនដំបូងចុះខាងខ្ញុំហ្នឹងលាក់កាំភ្លើងតិចណាស់តាមឃ្លាំង។ កាំភ្លើងតាមឃ្លាំងគេដកហើយ ចុះពួកខ្មែរក្រហមដកហើយ ទើបនឹងចប់នឹងបានគេហៅប៉ុលពតៗនោះណា៎ ហើយខ្ញុំក៏អត់ដែលស្គាល់សោះ ប៉ុល ពត មុខម៉េចដង។ ខ្ញុំមិនដែលនឹងឃើញប៉ុលពតដង។ ដែលគ្រោងវ៉ៃហ្នឹងណា ចាំមើលខ្ញុំ ដល់ឧទាហរណ៍ថានៅតែពីរថ្ងៃ បីថ្ងៃយើងផ្ទុះអាវុធណា៎ ក៏គេចាប់កាណុងកាំភ្លើងយើងទៅពីនេះ នៅដេអិន។

ដារ៉ាៈ នៅដេអិន?

ណុបៈ ពីព្រោះមេខ្មែរក្រហមវានៅហ្នឹងដេអិន ។ គេត្រៀមចាំបាញ់បុកនៅដេអិនហ្នឹងឯង តែវាបែកការណ៍ បែកការណ៍ហ្នឹងមកពី តាអឿន ដែរ ។ ដែលថាបែកការណ៍នោះណា៎ មានបែកការណ៍ពីណាបែកការណ៍ពីមេធំហ្នឹង គាត់ដូចថាគាត់ចាប់រំលោភស្រីភេទ វាអញ្ចេះទេ ដល់កាល ចាប់រំលោភស្រីភេទហ្នឹងកាលគេចាក់អាត់ឲ្យយើងស្ដាប់នោះណា៎ ។

ដារ៉ាៈ ប៉ុន្តែពូដឹង ក្រោយមកតាមរយៈគេចាក់ខ្សែអាត់?

ណុបៈ បាទ! តាមរយៈខ្សែអាត់

ដារ៉ាៈ មើលពូនិយាយមើល បែកយ៉ាងម៉េច?

ណុបៈ ដែលចាក់ខ្សែអាត់នោះឯងវាមានមនុស្សស្រីកោការបម្រើឲ្យ តាអឿន នោះណាស់

ដារ៉ាៈ តាអឿនមានស្រី?

ណុបៈ បាទ!ឲ្យមានស្រីខូចខិលគ្នាហើយ ក៏រៀបឲ្យនីរសា ក៏វាមិនព្រមមីស្រីនោះឯង វាមិនព្រម ក៏អានោះឯងក៏វាធ្វើបានមិនបានក៏មិនដឹងទេណា តានោះណា៎ បែបបានហើយមិនដឹងថា កាលមុនចេះតែបានអានេះឲ្យខ្ញុំមានប្ដីហើយមកធ្វើបាបខ្ញុំទៀត ។

ដារ៉ាៈ ដែលគេធ្វើបានខ្លួនហ្នឹងអ្នកស?

ណុបៈ បាទ! ដែលវាមានប្ដីហើយ ។ វាមានប្ដីហើយក៏វាមិនព្រមទេ ។ វាទៅប្ដឹងទៅខាងប៉ុលពត នោះឯង បានជាគេតាមដានគាត់យូរចំនួនពីរបីខែ បានចាប់នែ៎

ដារ៉ាៈ អឿន?

ណុបៈ អឿន នោះឯង ។ បានគេហៅពី អឿន នោះឯងតាមខ្សែរយៈទៅវា ស្ដីនែ៎...

ដារ៉ាៈ កុយ ធួន អីហ្នឹង?

ណុបៈ កុយ ធួន អី... តាពក នោះ ។

ដារ៉ាៈ តាពក?

ណុបៈ បាទ! នោះឯង ។

ដារ៉ាៈ ចុះម៉េចទៅទាក់ទង កែពក នោះវិញ?

ណុបៈ តាពក ហ្នឹងគាត់គណៈភូមិភាគកងពលដែរហ្នឹង ។

ដារ៉ាៈ ភូមិភាគខត្តរហ្នឹង?

ណុបៈ បាទ! ហ្នឹងឯងនៅខាងភូមិខត្តរ ។

ដារ៉ាៈ ជាមួយតាអឿន?

ណុបៈ ជាមួយតាអឿន ។ តាអឿនខាងកាន់ទ័ព ។ តាអឿន ខាងមេទ័ព

ដារ៉ាៈ ហើយតាពកហ្នឹង?

ណុបៈ តាពកហ្នឹងគឺទូទៅទាំងអស់ ខាងភូមិភាគឧត្តរ ។

ដារ៉ាៈ ខាងភូមិភាគឧត្តរ?

ណុបៈ បាទ! ខាងនយោបាយ

ឃិនៈ ប៉ុន្តែវិលទៅផ្នែកអីក៏បន្ទាប់ហ្នឹងដែរ?

ណុបៈ ក៏បន្ទាប់ហ្នឹង ។

ឃិនៈ ប៉ុន្តែហេតុអីបានជាគេមិនចាប់ កែពក? ម៉េចចាប់តែ តាអឿន កែពកម៉េចក៏ចាប់មិនបាន?

ណុបៈ គាត់មានខូច ។ គាត់អត់មានខូចនឹងមនុស្សស្រី ។

ដារ៉ាៈ ចឹងរឿងដែលចេញមុនដំបូងហ្នឹង គឺរឿងដែលទាក់ទងនឹងការ...

ណុបៈ តាអឿន រំលោភស្រី ។

ដារ៉ាៈ ការចាប់រំលោភស្រី? តា អឿន រំលោភស្រីនោះទេ?

ណុបៈ បាទ!

ដារ៉ាៈ ដល់ពេលហៅទៅសួរ គឺហៅទាំង កែ ពក ទៅដែរឬយ៉ាងម៉េច?

ណុបៈ អារឿងនោះខ្ញុំអត់ដឹងដែរណា ។ ចាប់ពីសម្ងាប់បាត់មុខអត់ដឹង ។ ចាប់សម្ងាប់បាត់មុខចាំមើលគេចាប់ណ៎ា គេមិនហៅហើយយើង យើងទៅចាប់កន្លែងគេទេ ដែលខ្ញុំនៅយល់នៅនោះណា គេឲ្យម៉ោឲ្យជិះមូតូ ជិះអីម៉ោទៅណ៎ា

ដារ៉ាៈ ម៉ោកន្លែងណ៎ា?

ណុបៈ ដូចថាកន្លែងគេនៅត្រង់ណា ដូចថានៅវត្តភ្នំនៅណាអញ្ចេះគេចាប់ម៉ោ គេចាប់ម៉ោមានពួកអាកងពិសេស ដូចពួកខ្ញុំថានោះណា អាពួកចេះវៃការ៉ាត់គេ វៃយូដូ វៃអីនោះណ៎ា

ដារ៉ាៈ បាទ!

ណុបៈ គេចាប់ហើយ ។

ដារ៉ាៈ ចាប់អ្នកណា?

ណុបៈ ចាប់អាពួកក្នាឯងនោះណ៎ា

ដារ៉ាៈ ចាប់អាអ្នកហាត់ប្រដាល់សេរីហ្នឹង?

ណុបៈ អត់ទេ ។ **ចប់ភាគ១**

ដាវ៉ាៈ តទៅទៀតទៅពូ ។ អញ្ចឹងហៅពួកដែលហាត់សេរី ដែល ជា សារ បង្ហាត់ដែលថា អាចបេះចាប់មនុស្សឲ្យអ្នកនោះទៅចាប់ ។ ទៅចាប់យ៉ាំងម៉េច?

ហាគៈ ចាប់ដូចថាជិះម៉ូតូមកចាប់ទៅ ។ ដូចថាយើងស្គាល់គ្នាធ្វើមេធំ យើងធ្លាប់ធ្វើកូន បើគេប្រើឲ្យចាប់ក៏នៅតែចាប់ដែរ ។ ចាប់ចងរួចទៅ អាអ្នកចាប់ ចាប់បានហើយគេបញ្ជូនទៅណាទៀតអត់ដឹងទេ ដួនកាលទៅឯព្រៃសអីយើងអត់ដឹងទេ អាអ្នកចាប់នោះណាដែលខ្ញុំនៅតាមឃើញដែលគេចាប់តាមថ្ងៃក៏ដោយ យប់ក៏ដោយ គឺនៅទូតកូរ៉េ ។

ដាវ៉ាៈ នៅម្តុំណាទូតកូរ៉េ?

ហាគៈ នៅផ្សារចាស់ អាត្រង់ដើមពោធិ៍មួយដើម ។

ដាវ៉ាៈ ទូតកូរ៉េ នៅមាត់ទន្លេហ្នឹង?

ហាគៈ អត់នៅមាត់ទន្លេទេអាតាមផ្លូវដើមពោធិ៍ អាកន្លែងគេរុំធុងមូលដាក់កាំភ្លើងខ្ញី ។

ដាវ៉ាៈ អូហ៍!

ហាគៈ ទូតបារាំងនៅខាងនេះ ទូតកូរ៉េនៅខាងកើតខាងជើងទេ អាធ្វើផ្ទះផុសផ្ទលាង លាបពណ៌លឿង ។

ដាវ៉ាៈ អញ្ចឹងដែរថាការក្សត់អីដែលថារៀបចំដោយតាអឿន ក្រុមរំលំខ្មែរក្រហមហ្នឹងមានមែនលោកពូ?

ហាគៈ មាន ។

ដាវ៉ាៈ ពូបានទទួលផែនការណ៍ហ្នឹងដែរ?

ហាគៈ ទទួលខ្ញុំនៅទួលគោកខ្ញុំនៅទទួលនោះហើយ ។ គេថាបើបែកការណ៍ អត់ពិបាកគេមកសម្លាប់ទេ សម្លាប់គ្នាឯង ឲ្យតែអ្នកណាបែកការណ៍ ដូចថាបែកការណ៍ហ្នឹងទៅរាយការណ៍ឲ្យខ្មែរក្រហម ។

ដាវ៉ាៈ ចុះបើលោកពូជាសម្ព័ន្ធយុវកក បើសិនជាប្រាប់មកបែកការណ៍យ៉ាំងម៉េចគេនឹងសម្លាប់ហើយ?

ហាគៈ បាទ! សម្លាប់ហើយ ។ តែសម្លាប់ហ្នឹងជាបុគ្គលគ្នាឯងទេ កាប់សម្លាប់គ្នាបន្ត ។

ដាវ៉ាៈ អញ្ចឹងមានការរៀបចំផែនការណ៍ក្សត់ហ្នឹងមែន?

ហាគៈ មានមែន ។

ដាវ៉ាៈ តែហេតុអីបានធ្វើទៅចេញវាមិនរួច ដោយសារពូនិយាយថាបែកការណ៍តាមរយៈល្មោភស្រីហ្នឹង ។ ពូនិយាយឲ្យច្បាស់មើលថាល្មោភស្រីអីយ៉ាំងម៉េច រៀបការអីម៉េច?

ហាតៈ វាអញ្ចេះកាលហ្នឹងមនុស្សស្រីដូចបំរើដូចជានិរសា ជាពេទ្យជាអី ។

ដារ៉ាៈ ហើយមនុស្សស្រីបញ្ចូលសម្ព័ន្ធឬនៅបើតាមដឹង?

ហាតៈ អត់ដឹងផង ព្រោះខាងនោះគេខាងពេទ្យ ។

ដារ៉ាៈ ហើយខាងស្រីហ្នឹងក៏មិនទាន់ដឹងដែនការណ៍ក្បត់របស់អឿនហ្នឹងទេ?

ហាតៈ ដឹងមិនដឹង ខ្ញុំអត់សូវដឹងដែរ ។

ដារ៉ាៈ ទី១ គឺមនុស្សស្រីហ្នឹងឯងពូអត់ដឹងថាចូលជាសម្ព័ន្ធយុវកកហើយឬនៅទេ ។ បើសិនជាចូលក្នុងសម្ព័ន្ធយុវកកដឹងពីបញ្ហាក្បត់ ព្រោះខាងលើគេប្រាប់មកអញ្ចឹងណា?

ហាតៈ បាទ!

ដារ៉ាៈ ប៉ុន្តែបើអត់ដឹងទេធ្វើពេទ្យធម្មតាទេ?

ហាតៈ បាទ!

ដារ៉ាៈ ហើយបើធ្វើពេទ្យធម្មតា បើសិនជាមានការចាប់រំលោភអីត្រូវប្តឹងយ៉ាងម៉េចពូ?

ហាតៈ គេទៅប្តឹងខាងប៉ុល ពត ។

ដារ៉ាៈ ហើយនារីហ្នឹងស្គាល់ឈ្មោះទេពូ?

ហាតៈ ខ្ញុំអត់ស្គាល់ដែរ គេប្រាប់ដែរគេចាក់ខ្សែអាត់ឲ្យយើង ។ ដែលប៉ុល ពតគេយកខ្សែអាត់ហ្នឹងមកចាក់ឲ្យយើងស្តាប់ ។

ដារ៉ាៈ ស្តាប់ហ្នឹងនៅក្នុងខ្សែអាត់សម្លេងនិយាយហ្នឹងសម្លេងពីណា?

ហាតៈ សម្តីគាត់តែម្តង ។

ដារ៉ាៈ ឮសម្លេងដូចថាច្បាស់និយាយដោយគ្មានការបង្ខិតបង្ខំ ដូចខ្ញុំនិយាយជាមួយពូអញ្ចឹង?

ហាតៈ បាទ! និយាយដូចយើងនិយាយអញ្ចឹង និយាយតាមដំនើររបស់គាត់ ។

ដារ៉ាៈ គាត់និយាយតែម្នាក់ឯង ឬក៏មានអ្នកសួរដែរ?

ហាតៈ គាត់និយាយតែម្នាក់ឯងតែម្តង ។

យិនៈ អាហ្នឹងបានន័យថាគាត់សារភាព ឬក៏អី?

ហាតៈ បាទ! គាត់សារភាពដឹង បានគេនិយាយពីសួរចំលើយហើយដឹងបានគេមកចាក់ខ្សែអាត់ក្រោយ ។ ចាក់ឲ្យយើងស្តាប់នៅតាមអង្គភាពដែលថាកូនចៅគាត់ ។ គេមិនប្រាប់យើងទេ គេប្រាប់ថាគេយកទៅរៀនហើយអឿននោះ តែមេនេះមកផ្សេងហើយ ប៉ុន្តែអឿន នោះស្លាប់ហើយឬនៅក៏យើងអត់ដឹងដែរ ។ មេគេចេញមកពីនិរតីអីទៀតហើយ

មកកាន់ភូមិភាគខត្តរយើងនេះ គេប្រកាសថាអឿន ហ្នឹងបានរំលោភស្រីគេបានយកទៅរៀនទោសូត្រ គេមិនថាគេយកទៅសម្លាប់ឯណា ។

ដារ៉ាៈ បន្ទាប់ពីសម្លាប់ហើយមានអ្នកចុះទៅរៀនសូត្ររៀនអីនៅកន្លែងពូទេ?

ហាតៈ អ្នកទៅបង្រៀនគេទៅបង្រៀនខ្ញុំតែនៅនេះទេ គេអត់មានបង្រៀនអីផង ដែលខ្ញុំចេញ ទៅគេចាប់ អឿននេះហើយគេថា មិនទុកទេកងពិសេសនាំឲ្យការបំផុសបំផុលគេចាប់តាំងពីមេកង។ គេសម្លាប់ចោលអស់ហើយ តែគេអត់ដឹងថាអាកូនចៅត្រូវជាសម្ព័ន្ធអីគេអត់ដឹងទេ គេដឹងដូចថាជាកងតូច កងធំអីគេសម្លាប់ទៅ កងតូចនៅទេ ។ គេបញ្ជូនខ្ញុំឲ្យទៅព្រលានយន្តហោះនៅកំពង់ឆ្នាំងនេះ ។

ដារ៉ាៈ ឆ្នាំណាកាលហ្នឹង?

ហាតៈ ឆ្នាំ៧៧ ។

ឃិនៈ អាហ្នឹងចុងក្រោយហើយ?

ហាតៈ បាទ!

ដារ៉ាៈ ចុងបញ្ចប់ហើយ អញ្ចឹងពេលដែលចាប់អឿន មួយហ្នឹងសភាពការណ៍នៅក្នុងកងពលឬក៏នៅក្នុងភូមិភាគខត្តរទាំងមូលហ្នឹងយ៉ាងម៉េចដែរលោកពូ?

ហាតៈ តាមតែចាប់បានមួយហ្នឹង គឺថាកម្លាំងអ្នកចាំតស៊ូវាបែកបាក់គ្នាអស់ហើយ វារាត់រាយអស់ហើយ ចុះមេផ្សេងហើយ មិនដឹងជាមកពីខាងណាខាងណីទេ វាមានការមិនទុកចិត្តដូចយើងមុនភ័យទាំងអស់គ្នាទៅ គេអ្នកមេៗ ។ អ្នកណាដឹងក៏ចេះតែភ័យទៅ បើដឹងក៏មិនដឹងទៅខាងណាមកខាងណី ។ តែអាបែកការណ៍ដែលថាយើងយកគណបក្សនេះយកគណៈបក្សនោះគេអត់មានដឹងទេ ពីព្រោះគេនោះគេដឹងថាយើងបំផុសទាំងអស់គ្នាហើយ តែគេចាប់យកតែមេ មេៗសម្លាប់អស់ ទុកត្រឹមកងតូច ប្រធានក្រុម ។

ដារ៉ាៈ អញ្ចឹងការដែលចាប់ហ្នឹងពូអាចរៀបរាប់បានទេ បន្ទាប់ពីការចាប់អឿនមកហ្នឹង មានចាប់ត្រឹមកម្រិតប៉ុនណានៅក្នុងកងពល?

ហាតៈ កម្រិតកងធំ ។

ដារ៉ាៈ កងធំគឺសំដៅលើមួយកងធំទាំងអស់ ឬក៏ជាមេនៅក្នុងកងធំ?

ហាតៈ ចាប់តែមេទេ ។

ដារ៉ាៈ ចុះកូនចៅដែលនៅក្នុងកងធំ?

ហាត: កូនចៅអត់មានចាប់ទេ គេទុកដើម្បីយកទៅធ្វើព្រលាមយន្តហោះ គេថាចាប់តែមេអស់ ហើយអត់មានអ្នកណាពីងទៀតទេ ។ គេថាគេផ្តាំទៅដូចថាអ្នកនៅភ្នំពេញ គេថាពួកកង ពិសេសគេយកទៅសម្លាប់ហើយគេមិនទុកទេ ។

ដារ៉ា: ពួកណាថា? ដឹងតាមរបៀបណា?

ហាត: ដឹងតាមរបៀបដែលខ្ញុំមកវិញ ដែលមកវិញគេមកពី ព្រោះខ្ញុំមកពីកំពង់ឆ្នាំងគេបញ្ជូន ហើយយួន វាមិនមកដល់ដីដុះ ។

ដារ៉ា: ដីដុះនៅភូមិណា?

ហាត: ដីដុះនៅកំពង់ចាមនេះ ហើយដល់ពួកតំបន់នេះគេមិនឡើងវៃ តំបន់ខាងគេហ្នឹងវៃអត់ ឈ្នះ ទើបបានទៅយកពួកខ្ញុំ៤០០, ៥០០នាក់ ដែលថាធ្វើយន្តហោះក្បាលត្រម៉េង១ មក យកទៅវៃវិញ ។ ហើយមកដល់តំនាក់កាលវៃនេះ ខ្ញុំនិយាយនេះវាវែងឆ្ងាយដែរ ប៉ុន្តែមកដល់នេះ ដែលខ្ញុំដឹងតំនឹងនេះមកដល់វត្តភ្នំវិញ ។

ដារ៉ា: ពេលដែលមកពីកំពង់ឆ្នាំមកដឹងនៅកន្លែងវត្តភ្នំនេះវិញ?

ហាត: បាទ! វត្តភ្នំវិញព្រោះពួកនោះឯង គេថាគេសម្លាប់ចោលអស់ហើយ ពួកនិរតីនេះគេ ប្រាប់ថាសម្លាប់ចោលអស់ហើយ ។ ខ្ញុំសួរអ្នកស្រី១ដែលធ្វើអ្នកដាំបាយឲ្យយើងហូប មុននេះណា សួរដូចថា ចំនាំមុខនេះទេ ក៏គេនិយាយថាឈ្មោះនេះគេយកទៅសម្លាប់ ចោលហើយ ។

ដារ៉ា: ចុះពូនិយាយមិញនេះណា ពូថាខាងនិរតីអ្នកសម្លាប់ ម៉េចបានពូដឹងថាខាងនិរតីអ្នក សម្លាប់?

ហាត: បើនិរតីយើងនេះវាបែកការណ៍ អានេះបើយើងថាពីដើមគេហៅថាពួកខាងចិន ។...

ដារ៉ា: អញ្ចឹងពីមុនពី៧៨នេះទៅ ពូអត់ដឹងថាមេអីណាទេ?

ហាត: អត់ដឹងទេ ទើបតែគេចាប់អឿននេះទៅ បានដឹងថាមេប៉ុល ពត យ៉ាងម៉េចដែរទេ ។ បែកភ្នំពេញហើយអត់មានប្រជាជនណាដើរកាត់នៅវាលនោះទេ តែស្រីមួយក៏មិន ដែលឃើញ សុទ្ធតែប្រុសទាំងអស់ ។

ដារ៉ា: ចុះពេលដែលចាប់អឿនហ្នឹងទៅ មានប្រកាសថាអ្នកណាជាមេធ្លោដឹកនាំ ខ្មែរក្រហមអី ទេ?

ហាត: នោះហើយថាដឹកនាំទៅខ្មែរប៉ុល ពតនេះឯង ។

ដារ៉ា: ពូឮតែប៉ុល ពតម្នាក់ ឬក៏ឮឈ្មោះផ្សេងទៀត?

ហាត: គ្រាន់តែឮថាប៉ុល ពត ខាងប៉ល ពតវានៅខាងនិរតី ហើយខាង តាពក ហ្នឹងគាត់នៅខាងភូមិភាគឧត្តរតែគាត់នៅរស់ទេ គេប្រកាសប្រាប់អញ្ចឹង ។ ហើយខាងស្វាយរៀង នោះ សោ ភឹម ខាងបូព៌ា ។

ដារ៉ា: អញ្ចឹងភូមិភាគមានបីទេអញ្ចឹង?

ហាត: ភូមិភាគមានតែបីទេ ។

ដារ៉ា: មានតែ ឧត្តរ និរតី បូព៌ា?

ហាត: បាទ!

ដារ៉ា: ហើយចុះពាយ័ព្យ អីមានដែរឮទេ?

ហាត: មានដែរ ប៉ុន្តែខាងណោះគេហៅខាងបច្ចឹម ។

ដារ៉ា: បច្ចឹមខាងកំពង់សោមអីហ្នឹង?

ហាត: បាទ!

ដារ៉ា: ខាងហ្នឹងអត់សូវមានលេចឮអីប៉ុន្មានទេ?

ហាត: បាទ! អត់សូវលេចឮអីប៉ុន្មានទេ ។ តែនៅក្នុងនេះវាមាននៅក្នុងបក្សដូចថាបក្សនៅក្នុងចំនោមធំដូចខ្ញុំថាអញ្ចឹង ។ ភាគច្រើនមកពីនិរតីក៏វាតិចដែរ ហើយមានតែភូមិភាគឧត្តរនិងភូមិភាគបូព៌ាកម្លាំងធំ ។

ដារ៉ា: កម្លាំងធំវៃច្រើនទៅភ្នំពេញហ្នឹង គឺឧត្តរនិងបូព៌ា?

ហាត: បាទ! ឧត្តរនិងបូព៌ាកម្លាំងធំម៉ង គេចេញទៅពីរមុខព្រួញហ្នឹង ។

ដារ៉ា: ខ្ញុំជួបមីសាន គាត់នៅក្នុងកងពល៣១០របស់តាអឿនដែរ គាត់នៅកំពង់ឈើទាល នៅស្រុកប្រសាទសំបូរ គាត់បាននិយាយរៀបរាប់ប្រហាក់ប្រហែលនឹងលោកពូដែរ ហើយខ្ញុំក៏បានសួរគាត់ដែរថា ចុះមីងមានឆ្ងល់ទេចុះហេតុអីគេចាប់តាអឿនហើយតាពកហ្នឹងប្រធានភូមិភាគទាំងមូលគេអត់ចាប់ អញ្ចឹងបើតាមពូយល់ថា ម៉េចដែរបានជាគេអត់ចាប់កែ ពក?

ហាត: គាត់អត់មានខូចខុសនឹងសីលធម៌ ។

ដារ៉ា: អញ្ចឹងរឿងរ៉ាវដែលចាប់ខ្លាំងមុនដំបូងហ្នឹងគឺទាក់ទងនឹងសីលធម៌?

ហាត: បាទ! សីលធម៌ហ្នឹង បានដឹងរឿងសីលធម៌ហ្នឹងមនុស្សស្រីហ្នឹងប្រហែលជាចូលនិវត្តដែរ ហើយ បានដឹងថាមានផែនការណ៍ បានគេតាមប្រហែលជាពីរខែហ្នឹងបានគេចាប់ខ្លួន បីខែហ្នឹងគេចាប់តាអឿនហ្នឹង បានគេពត៌មានមកឲ្យយើងមក ចាក់ខ្សែអាត់ឲ្យស្តាប់ ។

ដាវ៉ាៈ មីងសាន គាត់ក៏រៀបរាប់អញ្ចឹងដែរថា រឿងចាក់ខ្សែអាត់ៗ ខ្ញុំបានជួបពូ ចៀម អី អញ្ចឹងគាត់នៅប្រសាទសំបូរដែរគាត់នៅកងពលតាអឿនដែរ ។ ដល់ចាប់តាអឿន ហ្នឹង ទៅមានការប្រមូលយោធានៅក្នុងកងពល ចូលទៅវត្តភ្នំ ហើយចាក់ខ្សែអាត់ឲ្យស្ដាប់ អញ្ចឹងមែន?

ហាតៈ បាទ! អញ្ចឹងមែនចាក់នៅហ្នឹងឯងចាក់នៅវត្តភ្នំ ។ តែសុទ្ធតែទាហានទ័ពទាំងអស់ខ្មែរក្រហម ។

ដាវ៉ាៈ ពូថាដូចមានការហៅចេញម្ដងមួយៗ ទាក់ទងនឹងមេ ដូចថាកងពលអញ្ចឹងទៅ មានអនុកងពល បន្ទាប់មកកងវរសេនាធំ វាមានប្រធាន អនុប្រធាននិងសមាជិក ។ ហើយហៅចាប់អញ្ចឹងមែនឬក៏យ៉ាងម៉េច?

ហាតៈ ហៅចេញអញ្ចឹងមែន ហៅចេញមកនៅផ្លូវមកមាត់ទន្លេ ហៅចេញមកអញ្ចឹងមក ។

ដាវ៉ាៈ ដែលឃើញអ្នកដែលហៅចេញទៅ ហើយមកវិញនៅរស់រានមានជីវិត?

ហាតៈ អត់ដឹង អត់បានឃើញផង ។ ដល់អាពេលការហ្នឹងគេចាប់តាអឿនហើយថា បើទ័ពគេមួយត្រឹមកងតូច កងធំអីទេណា ហ៊ានះគេ គេត្រូវហៅ ឈ្មោះនេះៗគេហៅចេញទៅ ដល់ហៅចេញទៅគេមិនដឹងទៅណាគេប្រាប់ថាទៅរៀន ។

ដាវ៉ាៈ អញ្ចឹងវាបញ្ជាក់ពីខាងដើមវិញ ពូដែលថាពេលទៅចាប់ហ្នឹង ពូថាប្រើពួកអ្នកដែលហាត់ក្បាច់គុន?

ហាតៈ អារឿងក្បាច់គុននេះឯងជិតាន់នេះទេ ជិតាន់តែអឿននេះទេ ។ អាអឿនហ្នឹងដូចថាយើងចូលប៉ុននេះឯង វាបែកការណ៍ រាយការណ៍ដូចថាខ្មែរក្រហមហ្នឹង ត្រូវនឹងគេចាប់គ្នាឯង សម្លាប់គ្នាឯងកុំឲ្យវាបានដឹងទៅកន្លែងប៉ុល ពតវិញ ។

ដាវ៉ាៈ អញ្ចឹងមានន័យថាតាអឿនហ្នឹងគាត់បញ្ជាហ្នឹង ឲ្យអ្នកដែកចេះក្បាច់គុនហ្នឹង ចាប់អ្នកណាដែលដឹងដែនការណ៍បែកការណ៍ហ្នឹងយកទៅសម្លាប់ចោល?

ហាតៈ បាទ!

ដាវ៉ាៈ ប៉ុន្ដែនៅពេលថា ខាងខ្មែរក្រហមចាប់ខាងតាអឿននេះគឺប្រជុំចាក់មេក្រូឲ្យស្ដាប់សម្ដីរបស់តា អឿន នៅវត្តភ្នំហៅចេញមកក្រៅទេ?

ហាតៈ បាទ! ដល់គេមកប្រជុំ គេប្រកូកប្រកាសដែលចាប់តាអឿនហើយនេះណា គេហៅយើងមក នៅវត្តភ្នំនេះឯង គេសួរយើងថាម៉េចបាត់មេ ? កូនចៅនេះមកហើយបាត់មេទៅណា? គេថាអត់អីទេ គេយកទៅរៀនទេ ។

ដារ៉ាៈ កាលហ្នឹងអត់ទាន់ដឹងថាចាប់យកទៅសម្លាប់ទេ?

ហាតៈ ដូចថាមេ សោ គឹម ជាការចាប់អារម្មណ៍...ដល់ពេលរាងថ្ងៃទៅក៏គេចាប់ហៅបញ្ចេញហៅឈ្មោះ គេដឹងឈ្មោះអស់ហើយ ឯកសារហ្នឹងគេហៅឈ្មោះមេៗចេញចេញតាមមាត់ទ្វារច្រកតូចៗ ហើយពេលថ្ងៃដឹងគេចេញទៅណា? ហៅម្នាក់មួយៗឈ្មោះទៅ ។

ដារ៉ាៈ អញ្ចឹងពូពេលដែល ចាប់តាអឿនទៅមិនមែនរបៀបចាប់ទេ ជារបៀបគេហៅទៅ?

ហាតៈ បាទ! បើតាអឿន ខ្ញុំមិនបានឃើញទេណា គេហៅទៅឬមិនទៅខ្ញុំអត់ដឹងទេ តែបាត់ពេលដែលអង្គប្រជុំមកវាអត់ឃើញ ដល់អត់ឃើញគេថាមេទៅរៀនហើយកុំភ័យ មានគេមកជំនួស ។

ដារ៉ាៈ អញ្ចឹងដល់ពេលដែលពូបានស្តាប់ចាក់កាសែ្សតរបស់តាអឿនហ្នឹងសំដីដែលតាអឿននិយាយហ្នឹងពេលហ្នឹងពូគិតថា យ៉ាងម៉េច?

ហាតៈ ខ្ញុំមានអារម្មណ៍ថាគេយកទៅសម្លាប់ហើយ គ្មានអារម្មណ៍ថាយកទៅទុកបានទេកាលហ្នឹងព្រោះខូចខិលដល់១០០នាក់ហើយ ។

ដារ៉ាៈ ក្នុងខ្សែអាត់ហ្នឹងប្រាប់ថា១០០នាក់?

ហាតៈ បាទ!

ឃិនៈ គាត់រំលោភនារីហ្នឹង?

ហាតៈ បាទ! តាំងពីឆ្នាំចិតប៉ុន្មានអីប៉ុន្មាន ប្រាប់ពីនារីដែលគាត់រំលោភតាំងពីឈ្មោះ នៅតាមណាអី ។

ដារ៉ាៈ អញ្ចឹងពូឥឡូវថាចប់ត្រឹមថាចាប់តាអឿនហ្នឹង ហើយពីមុនមកពូក៏អត់ដឹងថាពីណាជាអ្នកដឹកនាំរបបខ្មែរក្រហមដែរ ។ ដែលចាប់ព្វហ្នឹងចាប់ពីពេលដែលគេចាប់តាអឿន ចាក់ខ្សែអាត់ហ្នឹងបានដឹងថាខ្មែរក្រហមហ្នឹងគឺមានប៉ុល ពត ។ អញ្ចឹងក្រៅពីប៉ុល ពតពូមានដែលព្វអ្នកណាទៀតទេ?

ហាតៈ ខ្ញុំអត់ដឹងដែរ ។ ទើបតែព្វក្រោយនេះ បើថាមុនអត់ដឹងទេ ។

ដារ៉ាៈ ចុះព្វថាក្រោយហ្នឹងតែប៉ុល ពតមួយទេ?

ហាតៈ បាទ! ព្វក្រោយដែលថាយើងព្វសព្វថ្ងៃនេះណា ។

ដារ៉ាៈ អញ្ចឹងពីមុនមកពូមិនដែលព្វទេ?

ហាតៈ បាទ! អត់ដែលព្វទេ ។

ដារ៉ាៈ អញ្ជើងពូត្រឡប់មកវិញ ពូនិយាយពីពូត្រឡប់មកវិញពីកំពង់ឆ្នាំងទៅសមរភូមិវែវៀត ណាមនោះ?

ហាតៈ ដល់មកនេះ ដែលខ្ញុំមកដល់វត្តភ្នំនេះគេថា កងពិសេសគេយកទៅសម្លាប់ហើយ ម៉េច ក៏រស់វិញ គេឆ្ងល់អញ្ជើងណា ។

ដារ៉ាៈ អញ្ជើងពូ នៅក្នុងកងពិសេស?

ហាតៈ បាទ!

ដារ៉ាៈ កងពិសេសតែនៅខាងក្រោយគេ អត់ទាន់វៃភ្នំពេញបាន?

ហាតៈ បាទ! ជាកង៣១០ដែរ ។

ដារ៉ាៈ តែជាកងពិសេសដែរ?

ហាតៈ បាទ!

ដារ៉ាៈ ហើយអញ្ជើងដល់ពេលទៅដល់វត្តភ្នំវិញទៅ អ្នកនោះសួរ?

ហាតៈ បាទ!

ដារ៉ាៈ អ្នកណាគេសួរហ្នឹង?

ហាតៈ ស្រីៗ អ្នកដាំបាយកាលយើងនៅស្គាល់គ្នាមុនហ្នឹង ផ្នែកដាំបាយរៀនអីគេអត់យកទៅ ណាទេ ។ ប៉ុល ពតឲ្យនៅដាំបាយដាំអីនៅហ្នឹងចុះ ជាមនុស្សស្រី ហើយយើងប្រុសៗ គេបញ្ជូនទៅនៅកំពង់ឆ្នាំង ហើយទៅនៅកំពង់ឆ្នាំងបានមួយឆ្នាំ បានគេបញ្ជូនមកនេះ វិញ គេវែងនេះខ្វាំងយើងនោះមានដឹងអី ។

យិនៈ ឥឡូវដល់ពេលមកដល់វត្តភ្នំវិញ គេបំពាក់អាវុធឡើងវិញ?

ហាតៈ អត់ទាន់បំពាក់ទេ ។ ដល់ទៅដល់ដីកំពង់ចាមនេះ បានបំពាក់ ។

យិនៈ ហើយបានទៅវៃទប់ទល់វៀតណាមទេ?

ហាតៈ បានទៅឡាន បានទៅទប់ទល់ផ្លូវរថក្រោះទៅ នៅមុខវត្តដីដោះផ្លូវទៅ ។

យិនៈ បានប្រយុទ្ធគ្នាទេ?

ហាតៈ បានទៅតាមនេះទៅ ក៏ឡានវៀតណាមគេមក ឡានគេនៅចំការកៅស៊ូនោះ ។ ទៅដឹង ថាឡានពួកយើងឡានកងពិសេសគេថាដូចជាមានពត៌មាននោះ វាថាពួកវៃនេះពួក ឆ្នាំ៧០ ៧១ ៧២ ៧៣ វាមកពីកំពង់ឆ្នាំង វារស់វិញទេ វាអត់ងាប់ទេ ។

ដារ៉ាៈ ខាងណាព្រៃនីងហ្នឹង?

ហាតៈ ខាងវៀតណាមនោះណា ។ ក៏វាអត់ក្រាញនៅវ៉ៃជាមួយកងពិសេសទេ វាបើកឡានរត់ទៅស្រុកវានោះ ទៅតាមកញ្ចូង ផ្សារក្រដាស ។

ដារ៉ាៈ គ្រាន់តែឮថាកងពិសេស ដែលវ៉ៃ ៧១ ៧២ មកហ្នឹង?

ហាតៈ បាទ! វាអត់នៅវ៉ៃទេ ។

យិនៈ ហេតុអីបានវាអត់វ៉ៃ?

ហាតៈ ដឹងម៉េច ខ្ញុំអត់ដឹងដែរ ថាអត់វ៉ៃចេះដាក់មីនអញ្ចេះ ឡានចេះតែដេញវាអញ្ចេះ ឡានផ្ទុះមីនឲ្យហែរតាមផ្លូវនេះ វាអត់វ៉ៃ ។ ដល់តែវ៉ៃបានទៅទប់នៅផ្សារក្រដាស ដល់វ៉ៃៗទាល់តែចប់ ប៉ុន្តែខ្ញុំអ្នកពិការណា ។

ដារ៉ាៈ ពិការត្រង់កន្លែងណា?

ហាតៈ ពិការត្រូវដៃត្រូវស្មា គេឲ្យមកវិញ ។ គេឲ្យមកវិញក៏ខ្ញុំមកនៅកំពង់ឆ្នាំងនៅផ្សារក្រោមនេះ ។

ដារ៉ាៈ មកវិញទៀតហើយអញ្ចឹង?

ហាតៈ គេឲ្យបញ្ជូនអ្នកពិការ គេអត់ឲ្យទៅមុខទៀតឯណា ខ្ញុំទៅបានមួយខែមកវិញ ។

ដារ៉ាៈ ពិការត្រូវដៃអីគេ?

ហាតៈ ដៃនេះ ។

ដារ៉ាៈ កូនដៃខាងស្ដាំនេះ?

ហាតៈ កូនដៃ ហើយស្មា ក ។

ដារ៉ាៈ ត្រូវរបួសពេលចូលសមរភូមិ?

ហាតៈ បាទ! ពេលចូលសមរភូមិ កាលហ្នឹងគេឲ្យរត់និរសា ។

ដារ៉ាៈ និរសាឲ្យអ្នកណា?

ហាតៈ និរសាឲ្យតាមខ្សែត្រៀមណា តាមប្រធានកងពលធំគេឡើងបញ្ជា កងតូចអីឡើងបញ្ជា ហើយខ្ញុំរត់ ។

ដារ៉ាៈ អញ្ចឹងពេលបញ្ជាហ្នឹង គេប្រើនិរសាហ្នឹងទេ?

ហាតៈ បាទ! ប្រើនិរសារត់តាមមុខសមរភូមិ គេប្រើដូចថា ឡើងចុះ ចេញ ចូលអីហ្នឹងណា ។

ដារ៉ាៈ អញ្ចឹងពេលដែលទៅវ៉ៃវៀតណាមហ្នឹងពូដឹងថាអ្នកណាជាមេកើយអីច្បាស់លាស់ទេ?

ហាតៈ អត់ស្គាល់ទេ ។

ដារ៉ាៈ ចុះពូនៅកងអីក្រុមអីទេ?

ហាគៈ ខ្ញុំកាលនៅនោះឯង ខ្ញុំមិនដែលស្តាប់ក្រុមអីស្រួសបួលផង កូនក្មេងនិយាយ កូនក្មេងកំពស់នេះឯងទៅនៅក្តាប់ខ្ញុំនោះ មិនដែលចេញពីគ្រង់សេផង នៅតែក្នុងគ្រង់សេ ។ គេថាខ្ញុំមិនដែលវៃមិនដែលអីផង គេឲ្យមក មកតាមតែគេ ។

យិនៈ ហើយមកធ្វើជាមេក្រុមទៀត?

ហាគៈ ធ្វើជាមេក្រុមយើង ។

ដារ៉ាៈ ពួកក្មេងៗហ្នឹងមកពីខាងណា?

ហាគៈ គេថាខាងនិរតី និយាយ ឆ្ងាយ និយាយ ផ្នែកនិយាយអីហ្នឹងមិនដឹងខាងណា មានតែខាងនោះហ្នឹង ។

យិនៈ និយាយល្អីនៗហ្នឹង?

ហាគៈ បាទ! និយាយឆ្ការ ខាងនិរតីជាទូទៅ ។

ដារ៉ាៈ ហើយអញ្ចឹងពូត្រូវរបួសហ្នឹងនៅឆ្នាំណា?

ហាគៈ ៧៨ ៧៩ហ្នឹង ជិតបែកទប់វៀតណាមទប់ចុងក្រោយ ។ ចុះខ្ញុំមកវិញបានប៉ុន្មាន បីបួនខែគេវៃបែកហ្នឹង ។ ខ្ញុំមកដេកពេទ្យនៅភ្នំពេញរួច បានគេជាចេញពីពេទ្យហើយគេបញ្ជាឲ្យទៅធ្វើត្រី នៅផ្សារក្រោមកំពង់ឆ្នាំងនោះ ។

ដារ៉ាៈ អត់ទាន់បែកខ្មែរក្រហមទេពេលហ្នឹង?

ហាគៈ អត់ទាន់ទេ ។

យិនៈ ទ័ពហ្នឹង ទ័ពខាងធ្វើត្រី?

ហាគៈ បាទ! អ្នកពិការគេឲ្យនៅដាំបន្លែដាំអីទៅ ព្រោះប្រើការមិនកើត ។

ដារ៉ាៈ ទាល់តែប្រើការមិនកើតបានគេលែងឲ្យទៅៗ?

ហាគៈ បាទ គេឈប់ឲ្យទៅវិញ ។

ដារ៉ាៈ ហើយចុះពូនៅធ្វើត្រីដល់ពេលណាទៅបានផុតរួចមកដល់សព្វថ្ងៃហ្នឹង?

ហាគៈ ដូចថាកាលនោះកប៉ាល់ហោះពីរ វាឡើងពីពោធិ៍ចិនតុងនេះទៅ គេមិនហោះតាមនេះ ឯងគេបើកទៅ ប៉ុន្តែយើងមិនដឹងអ្នកណា អ្នកណាទេ ក៏បើកទៅក៏ឃើញទៅលិចវិញកប៉ាល់ហោះហ្នឹង ក៏ពួសូរស្នូរកាំភ្លើងនៅភ្នំពេញ ហើយចេះតែជំនុំគ្នាថាគេវៃនៅភ្នំពេញហើយ ដល់ថាវៃភ្នំពេញហើយ បាន១ ឬ២ថ្ងៃ បានឃើញឡានយួនមក ក៏បែកគ្នាទាំងអស់រលីង ។ ខ្ញុំចេះតែដើរទៅលិចតែម្តង ។

យិនៈ និយាយពីយន្តហោះហ្នឹងហោះរបៀបម៉េច ហោះទម្លាក់គ្រាប់បែក ឬក៏ហោះ យ៉ាងម៉េច?

ហាគៈ អត់ទេ ហោះហ្នឹងហោះអ្នកធ្វើដំនើរទេ អ្នកដូចថាមេៗគេ គេរត់ មេប៉ុល ពត យន្ត ហោះគេអា កន្ទុំរុយគេនេះៗ មេគេរត់ទៅនោះហើយខ្ញុំឃើញកប៉ាល់ហោះកាត់តាម នោះ គេហោះមិនហោះខ្ពស់ទេ ទាបល្មមៗ រួចយើងក៏ចេះតែដើរតាមស្រុកភូមិគេ ទៅដល់ឯពោធិ៍សាត់ ក៏គេយន្តដាក់កាំភ្លើង អា១៣០អីគេឆ្លងទៅបាត់ដំបងៗ

ឃិនៈ ខ្ញុំសូមបញ្ជាក់ត្រង់នេះបន្តិច ព្រោះថាការដែលឲ្យទ័ពស្តាប់ខ្សែអាត់ របស់ឈ្មោះអឿន ហ្នឹងក៏មាន សម្លេងកុយ ធួន ហៅធុចហ្នឹងដែរ?

ហាគៈ កុយ ធួន ខ្ញុំមិនបានចាប់អារម្មណ៍ដែរៗ

ឃិនៈ ប៉ុន្តែសម្លេងដែលពូស្តាប់ហ្នឹងពុំតែអឿនទេ?

ហាគៈ បាទ!

ដារ៉ាៈ មានដែលស្តាប់អ្នកផ្សេងទៀតទេលោកអ៊ី?

ហាគៈ អត់ដែលបានស្តាប់ទេៗ គាអឿនច្បាស់មែនទែនព្រោះជាមេៗ

ដារ៉ាៈ ចុះបើពូជាសម្ព័ន្ធធ្លាប់ទទួលការរៀនសូត្រផ្ទាល់ពីគាត់ហើយៗ ចុះគាអឿនហ្នឹងរាងវៅ យ៉ាំងម៉េចលោកពូ?

ហាគៈ រាងសង្ហាគ្រាន់បើដែរ កម្ពស់១,៦០មៗ

ឃិនៈ ប៉ុន្តែដឹងថាអឿនហ្នឹងមានប្រពន្ធហើយឬនៅ?

ហាគៈ អត់ដឹងដែរៗ បើប្រវត្តរបស់គាត់ប្រពន្ធកូនបែបអត់មានទេ បើតាមស្មានទៅៗ ខាង គាត់នៅខាងកំពង់ចាមនេះដែរទេ គាត់រាងខ្មៅស្រអែមល្មមៗ

ដារ៉ាៈ សក់របៀបម៉េច ?

ហាគៈ សក់ស្កួតៗ មើលទៅរាងគាត់សង្ហាៗ

ដារ៉ាៈ ហើយដែលអត្តុយស្តាប់ផ្ទាល់ដែលគាត់ឃោសនាពីរឿងនយោបាយ ដែលស្តាប់ផ្ទាល់ មាត់គាត់ទេ?

ហាគៈ បាទ! ស្តាប់ផ្ទាល់មាត់ បានខ្ញុំស្គាល់ច្បាស់ចាក់សម្លេងអាត់មក ជាសម្លេងអឿន ជា សម្លេងក្រលួៗៗ

ដារ៉ាៈ អញ្ចឹងពីពូរៀបរាប់ពីកាណុង១៣០ ដែលវៀតណាមដឹកទៅហ្នឹង?

ហាគៈ ដឹកទៅ ខ្ញុំទៅមើលពួកវៀតណាមហ្នឹងអត់ឲ្យទៅជិតទេ ក៏ខ្ញុំដេកនៅនេះឯង ដេកនៅ ជាយវៀតណាម ដេកទៅក៏ពួកខ្មែរក្រហមមកវ៉ៃពីខាងត្បូងមកវិញ នៅវ៉ៃកន្ទែង រ៉ាវទេះភ្លើង ក៏ខ្ញុំភ័យខ្ញុំថាខ្លួនឯងនេះមិនដឹងរត់ទៅណាមកណីទេ ក៏នៅជិតៗយួន ដល់

តែយួនគេឡើងឡានគេបាត់ទៅ ក៏ខ្ញុំនេះគេលគោលទៅ ក៏នៅមោងឬស្សីនេះ ក៏ទ័ពខ្មែរក្រហមគេមកយកម្ដងទៀត ។ គេដើរមកពីណាពីណីទេ គេចាប់ដើរស្រាវជ្រាវរកពួកចាស់ៗទៅវិញ ។

ឃិនៈ ហើយអញ្ជឹងក្រុមពួងឯងច្រើនគ្នាទេ?

ហាតៈ ខ្ញុំនោះប្រហែល៣០ ៤០ នាក់ដែរណា ។

ដារ៉ាៈ នៅជាមួយវៀតណាមក៏នៅចំនួន ៣០ ៤០នាក់ហ្នឹងដែរ?

ហាតៈ បាទ! ដែលច្រើនដេករកាក់រកូត ដេកនៅជាប់នៅជាយរបងផ្ទះគេនោះណា ។

ដារ៉ាៈ មានអាវុធទេកាលនោះ?

ហាតៈ អត់ទេ មានទេកាំបិតយើង ។ មានកាំភ្លើងអី យួនវាមិនចង់ទូឯងឯងផង ដើរជាមួយ ។

ដារ៉ាៈ អត់សួរទេ?

ហាតៈ បាទ! អត់សួរ ចេះតែទៅ ។

ដារ៉ាៈ ហើយក្រោយមកម៉េចទៀត?

ហាតៈ ក្រោយមកខ្មែរក្រហម ចាប់ឲ្យនៅភ្នំ ។

ដារ៉ាៈ ដឹងថាកន្លែណាៗអីដែរមកចាប់យកទៅ?

ហាតៈ ខ្ញុំថាអត់ដឹងកន្លែណាផង នៅក្នុងព្រៃទៀត មិនបានចាប់អារម្មណ៍ថាគេយកទៅនៅហ្នឹងព្រៃហ្នឹងមក ក៏នៅបានប្រហែលជិតមួយវស្សា ។ ហើយបានខ្ញុំមានវិទ្យុមួយយកទៅគ្រាន់ស្ដាប់ប៉ុស្ដិ៍អាមេរិកាំង ។ យប់ៗឡើងខ្ញុំចាំស្ដាប់ប៉ុស្ដិ៍អាមេរិកាំងថា នៅជួរភ្នំក្រវាញមានទាហានខ្មែរក្រហមឡើងចំនួនពីរសប្ដាហ៍ហើយ គេរាយការណ៍គេ ។ ហើយក៏ខ្ញុំភ័យខ្លាច ភ័យខ្លាចយួនមកទៀតនោះ ហើយខ្ញុំក៏ចូលមកសារភាព ។

ដារ៉ាៈ ចូលមកសារភាពវិញ?

ហាតៈ បាទ!

ដារ៉ាៈ អញ្ចឹងដោយសារបានស្ដាប់វិទ្យុហ្នឹង?

ហាតៈ បាទ!

ដារ៉ាៈ សារភាពមុនដំបូងសារភាពនៅឯណាពូ?

ហាតៈ នៅមោងឬស្សី បាត់ដំបង ។

ដារ៉ាៈ ពេលចូលសារភាពហ្នឹងគេមានសួរនាំអីទេ?

ហាតៈ គេសួរនាំថា នៅក្នុងនោះឯង មានខ្មែរឈ្មោះខ្មែរក្រហមប៉ុន្មានៗណា ។ ហើយខ្ញុំប្រាប់គេតាមភូមិ ឃុំទៅណា ថ្នាក់ឃុំសួរទៅ គេថាឲ្យខ្ញុំទៅវិញ ។ ឲ្យខ្ញុំទៅធ្វើនយោបាយ ធ្វើម៉េចឲ្យគ្នាខ្ញុំសួរថា ចុះបើសិនយើងមកសារភាពនេះ ហ៊ានទៅវិញដែរ? ហើយខ្ញុំថា ហ៊ាន ប៉ុន្តែអត់ឲ្យជួបមេបានទេ ។

ដារ៉ាៈ ចុះខាងភូមិ ឃុំនៅមោងហ្នឹងដែលគេប្រាប់អញ្ចឹង?

ហាតៈ បាទ! គេប្រាប់អញ្ចឹងឯង គេប្រាប់ថា ទៅគេឲ្យអង្គរ ឲ្យគ្រាប់កាំភ្លើងយើងនៅ ដដែល ។

ដារ៉ាៈ កាន់កាំភ្លើងអីដដែលហ្នឹង?

ហាតៈ កាន់កាំភ្លើងអីដដែលហ្នឹង ។ ទៅហៅគ្នាមក ដូចថាខ្សឹបប្រាប់អូនឯងអញ្ចឹងទៅ ក៏អូនឯងថាខ្លាចមិនហ៊ានមក ខ្លាចយួនគេអារក ជាទូទៅមេគេនៅនោះគេពន្យល់អញ្ចឹងនោះ ខ្ញុំថាអត់អីទេ គេទៅហូរហែតើ ។ ក៏បបួលគ្នាមក មកច្រើនណាស់ បានបួនប្រាំរយនាក់ឯណោះ ។ បានមកអញ្ចឹងទៅ ក៏មនុស្សចេះតែមកហូរហែអញ្ចឹងទៅណា ។

ដារ៉ាៈ អញ្ចឹងដោយសារតែលោកពូចូលទៅព្រៃវិញបានគ្នាច្រើន?

ហាតៈ ហៅបានគ្នាច្រើន គេឈប់ប្រើខ្ញុំហៅបានកម្លាំងច្រើនហើយ ទាហានវាអត់ឲ្យខ្ញុំដើរ ទៀតប្រើផ្សេងទៀតទៅ ។ គេទាហានយើងសព្វថ្ងៃនៅសាលាមោង ថាគាត់ទៅញឹកពេកកុំឲ្យគាត់ទៅអី ។ ផ្លូវជិតដល់ដែនការណ៍ទៅវៃនៅបរប៉ៃលិនហើយ ក៏ខ្ញុំគេបញ្ចូលអង្គភាពវៀតណាម បានទៅនៅបរប៉ៃលិន បានមួយឆ្នាំ ខ្ញុំនៅពេលបែកហើយភ្នំខៀវអីណា គេឲ្យទៅយករបងបន្លាលួសនេះទៅធ្វើតាមព្រំប្រទល់ខ្មែរហើយនិងថៃ ។

ដារ៉ាៈ សម័យនោះគេហៅថា ក៥ហ្នឹង?

ហាតៈ អត់ទេ ខុសគ្នា ខ្ញុំខាងទាហាន តែពេលហ្នឹងវាអត់មានមនុស្សឡើងណាក៏ខ្ញុំឡើងទៅធ្វើនោះដែរ យកទៅ ។ កាលនោះខ្មែរក្រហមនៅមែនណា អូម្ចាស់ម្នាក់ទឹកអូរ ខ្មែរក្រហមវាឃើញខ្មែរអត់បាញ់ទេ បើឃើញយួនវាបាញ់ វអង្គុយចាំទឹកអញ្ចឹង ។

ដារ៉ាៈ យួនចូលមកដងទឹកវាបាញ់?

ហាតៈ បាទ! តែយួនអត់ទៅទេ យើងប្រាប់ហើយថាកុំទៅ ។

ដារ៉ាៈ មានតែខ្មែរយើងទៅ?

ហាតៈ បាទ!

ដារ៉ាៈ អញ្ចឹងពេលណាដែលពូមកដល់ ភូមិ ស្រុកពូវិញ?

ហាតៈ ខ្ញុំមកពីបរប៉ៃលិនវិញ បានមកវិញគេមករើសធ្វើទាហាន ខ្ញុំនៅអន្លង់វិល ។ ខ្ញុំមកពីនោះវិញខ្ញុំកើតគ្រុនចាញ់ ក៏គេយកខ្ញុំទៅដេកនៅពេទ្យសៀមរាប អាហ្នឹងបានប្រាក់ខែហើយណា មួយខែបាន៦០រៀល ៥០រៀល ទៅតាមឋានៈយើង ។

ដារ៉ាៈ ចុះកាលហ្នឹងលោកពូបានឋានៈអីដែរ?

ហាតៈ ខ្ញុំបានឋានៈប្រធានក្រុម បាន៦០រៀល ។ រួចបានគេនាំមកនៅអន្លង់វិល បាត់ដំបង ។ ហើយខ្ញុំជា ហើយគេបញ្ជាទៅបរប៉ៃលិនវិញ គេឲ្យឡើងធ្វើជាប្រធានកង ។ ប៉ុន្តែតានោះអ្នកទៅរៀនហាណូយ គេបានធំជាងយើងទៀត គេមិនមែនអ្នកតស៊ូទេ តែគេចេះតម្រិះវិជ្ជា គេបានទៅរៀនអក្សរអី គេមកធ្វើមេយើង គេមិនចេះវ៉ៃអី ក៏គេចេះជាងយើងដែរ ព្រោះគេចេះខាងនយោបាយ ។ ខ្ញុំថាមានអី ទៅម៉េចបើខ្ញុំចាញ់ម្តងហើយមិនដឹងទៅយ៉ាងម៉េចទេ ក៏ថារត់ តែមិនបានប្រាប់គេទេ ក៏ឈ្មោះអាផលថាកុំទៅយើងទៅចាញ់ណាស់ ឥឡូវយើងរត់ ។ ចុះចាញ់អស់ហើយ ។ គេនៅនេះឃួនគេបើកទឹកដោះគេម៉្យា ខ្ញុំហូបទៅគ្រុនរាគតែម្តង រាគរហូតទាល់តែហេវតែម្តង ហើយគេឲ្យមកវិញគេបញ្ជូនអង្គភាពហ្នឹងឲ្យមកវិញមកមួយឆ្នាំហើយ ។ ដល់មកវិញមកដល់អន្លង់វិលនេះបានគេចាប់ធ្វើទាហាន ។

ដារ៉ាៈ រើសចាប់ធ្វើទាហានអីបើពូធ្វើទាហានស្រាប់ហើយ?

ហាតៈ អត់ទេ ចាប់អ្នកស្រុកយកទៅ ដែលថាគេចាប់ទាហានៗនោះឯង ខ្ញុំមកដល់ដំនាក់នោះឯងប៉ុន្តែឆ្នាំប៉ុន្មានទេខ្ញុំភ្លេចហើយដែលទូទៅហើយ ខាងណាក៏ថាខ្លាចគេចាប់ទាហាននោះ ។

ដារ៉ាៈ បើតាមខ្ញុំដឹង៨៩ ៩០ ហ្នឹងហើយ ៨៨ ៨៩ ៩០ ហ្នឹង ។ ព្រោះដែលខ្ញុំចាំព្រោះខ្ញុំរៀននៅភ្នំពេញ ហើយកាលហ្នឹងមានពូថាចាប់ទាហានមែន ព្រោះជិតដកវៀតណាមចេញនោះ ។ ហើយយ៉ាងម៉េចទៀតទៅលោកពូ?

ហាតៈ ក៏ខ្ញុំមកនៅអន្លង់វិលហ្នឹងបានខ្ញុំរត់ចេញពីនោះឯង ដូចថាស្អែកគេបញ្ជូនទៅបរប៉ៃលិនខ្ញុំលួចរត់ចេញយប់ហ្នឹងទៅ ។

ដារ៉ាៈ រត់មកផ្ទះ?

ហាតៈ អត់រត់មកផ្ទះទេ រត់មកជ្រកនៅកន្លែងខេត្តដែរ ប៉ុន្តែផ្ទះអ្នកស្រុកគេណា ក៏គេជាបងប្អូនអ្នកស្គាល់គ្នានោះណា ក៏ខ្ញុំទៅជ្រកពីរនាក់ ក៏ខ្ញុំអត់មានលុយទេប្រាក់ខែចាយអស់ហើយ ។ ខ្ញុំក៏ពឹងពាក់ប្រជាជននៅស្រុកគេនោះឯងគេមានលុយ គេឲ្យខ្ញុំរត់រកស៊ីទៅទិញសារុង ទិញបារីទៅជាមួយគេ ក៏ខ្ញុំទៅទិញសារុង ទិញបារីទៅលក់ជាមួយគេនៅ...

ប៉ុន្តែសិទ្ធិនៅទាហានដដែល ខ្ញុំមានកាតហាន ណួយផង តាំងពីស្គាល់កែ ប៊ុនថា ហៅ កុយ បៀន គណៈខេត្តបាត់ដំបងគាត់ឲ្យក្រដាសគេមកពីហានណួយជាប់គណៈខេត្តបាន ខ្ញុំចេញចូលវៀតណាមបាននោះ ប៉ុន្តែខ្ញុំមិនសូវចេះស្តាប់ភាសាគេទេ ចេះតែមួយមាត់ពីរមាត់ទេ ដល់បានលុយក៏ខ្ញុំជិះឡានមកនៅស្រុកខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ។

ដារ៉ា៖ បើនិយាយពីនៅក្នុងសម័យខ្មែរក្រហមលោកពូ ឆ្លងកាត់ពេញតែម្តង ព្រោះតាំងពី៧៤ រហូតមកដល់៧៩ ហើយធ្លាប់ធ្វើទាហានធ្វើអីមក ។

ហាគៈ បាទ! ចេញចូលៗ ។

ដារ៉ា៖ អញ្ចឹងក្នុងមួយអំឡុងពេលហ្នឹង ពូមានដែលជួបប្រទះនឹងអំពើឧក្រិដ្ឋកម្មអីមួយដែលពូឃើញផ្ទាល់ភ្នែកទេ ដូចថារំលោភ រំលោភ វៃវត្តអារាមអី?

ហាគៈ អត់សោះ ។

ដារ៉ា៖ ប៉ុន្តែពូធ្លាប់ឃើញគេហៅទៅរៀនសូត្រអីអញ្ចឹង?

ហាគៈ បាទ! ឃើញមានអញ្ចឹងមែន ខាងខ្ញុំវាអត់មានចាំផ្តេសផ្តាសទេ គេច្រើនតែហៅទៅ រៀន គេយកកម្ទាំងជាដុំធំចង រយៈរយោងទៅ គេដូចថាហៅសម្ងាត់ៗទៅទេ គេហៅដូចថាស្លូលគេអញ្ចឹងគេហៅចេញទៅមួយឬពីរទៅ យើងក៏អត់ដឹងដែរ ។ ទៅបាត់មួយថ្ងៃហើយ គេចេះតែថាជួនកាលគេថាបាត់មួយថ្ងៃបន្តិចនោះណា យើងសង្ស័យហើយ ប៉ុន្តែយើងក៏ដឹងដែរ តែចាប់ហើយមិនសាយរកទេ ។

ដារ៉ា៖ កាលជំនាន់ហ្នឹងដឹងអញ្ចឹងម៉េង?

ហាគៈ បាទ! តែចាប់ហើយដឹងថាគេយកទៅរៀនអញ្ចឹង ខ្លះដូចថាគ្នានៅដាំបាយទុកបាយឲ្យប្រធានគាត់រាល់ថ្ងៃ ចុះបើបាត់មួយថ្ងៃហើយ មួយថ្ងៃទៀត ចេះតែថាតែបាត់មួយថ្ងៃហើយ មួយថ្ងៃទៀតហើយ វាគ្មានតែនៅទេ តែមនុស្សហ្នឹងមិនដឹងជាយកទៅសម្លាប់ឲ្យគេឃើញឬមួយសម្លាប់បិទមុខមិនដឹងទេ ដឹងតែស្លាប់រឿងរស់គឺគ្មាន ។ ប៉ុន្តែយើងចេះភ័យព្រោះមានរបកមានស្នាមហើយចេះតែភ័យដែរ ខ្លាចបែកការណ៍ដែរ ។

ដារ៉ា៖ ហើយចុះកាលដែលពូទៅវៃនៅសមរភូមិវៀតណាម នៅកំពង់ចាមអាហ្នឹងតើពូមានការប្រជុំដាក់ផែនការណ៍ឬក៏មានការជំរុញអីដាក់វៀតណាមអីអត់ទេ មានជាឯកសារមានជាអីទេ?

ហាតៈ ខាងខ្ញុំដែលគេចាប់ទៅនោះគេរំលត់រំលាយអស់ហើយ គេឈប់នេះហើយដូចថា... គេទៅដល់ចាប់ចូលបណ្តោយអត់មានពិបាកដឹងថាអ្នកចេះវ៉ៃហើយអីទេណា វាគ្រាន់តែមេនាំទៅ ។

ដាវ៉ាៈ ចុះនៅពេលដែលអំឡុងវ៉ៃវៀតណាមតទល់គ្នា គឺថាមានការបាញ់សម្លាប់ ចាប់រំលោភប្រជាជនវៀតណាម ឬក៏ខាងវៀតណាមសម្លាប់ ចាប់រំលោភ មកលើប្រជាជនស្លូតត្រង់អីទេ?

ហាតៈ អានោះខាងខ្ញុំ បើនិយាយរួមទៅ ឲ្យតែអ្នកកងពិសេស អត់បានចូលរួមវ៉ៃនិងគេទេ ។

ដាវ៉ាៈ ម៉េចអញ្ចឹង?

ហាតៈ បានតែចូមកសើបការណ៍ ដាក់មីន ហើយនិងដោះមីន ដែលខ្ញុំទៅនៅខាងវៀតណាម ។ ចំការមីននៅត្រង់ណាគេប្រើហើយ ម្នាក់គឺបាន២អំរែកមក យើងមួយអំរែក គេមួយអំរែក អាមីនគោន អាអី...

ឃិនៈ ដោះមីនខាងណា?

ហាតៈ ដោះមីនខាងយួន ។

ដាវ៉ាៈ នៅពេលដែលពូចូលក្នុងជួរខ្មែរក្រហមហ្នឹង ពូនៅក្នុងកងពិសេសរហូតមក?

ហាតៈ បាទ! រហូតមក ។

ដាវ៉ាៈ ហើយកងពិសេសហ្នឹងធ្វើអីខ្លះ?

ហាតៈ កងពិសេសហ្នឹង សម្រាប់ដោះមីន ស៊ើបការណ៍ ។

ដាវ៉ាៈ អញ្ចឹងពូមានធ្លាប់រៀនដោះមីនអីទេ?

ហាតៈ ធ្លាប់រៀនតាំងពីហូរហែ ហើយណា ។ រឿងការដោះមីនហ្នឹងរៀនតាំងពីមុនដំបូង មុនវ៉ៃទាហានហ្នឹងម៉្លេះ ។

ដាវ៉ាៈ ពូរៀននៅណា រៀនដោះមីនហ្នឹង?

ហាតៈ ដើររៀននោះវាមិនទៀងទេ រៀននៅក្នុងព្រៃអីដែរហ្នឹង ។

ដាវ៉ាៈ ប៉ុន្តែពូស្គាល់ម៉ងរឿងដោះមីន?

ហាតៈ ទេថាស្គាល់ក៏មិនថា ដូចថាមិនទុកចិត្តខ្លួនឯងហ្នឹងណា ។ គ្រាន់តែអាចដឹង ដូចថាពុកមាត់បង្កងគេដាក់កប់អីអញ្ចេះ ហើយជួនកាលគ្រាប់បែកភ្លើងដាក់ដាក់ស្តែងម៉ង រត់ឆេះខោឆេះអាវតែម្តង ដូចថាថ្ងៃអញ្ចឹងគេរុំភ្នែកយើង ឲ្យយើងរាវ ដំនើរដើរ ដៃជាន់យ៉ាង ម៉េច ។ មកដល់រាល់ថ្ងៃចងចាំខ្លះដែរ ។

ដារ៉ាៈ អញ្ចឹងក្នុងមួយឆាកជីវិតពូដែលធ្វើខ្មែរក្រហមច្រើនអញ្ចឹងហើយរហូតមកធ្លាប់ធ្វើទាហានខាងវៀតណាមវ៉ៃខ្មែរក្រហមវិញអញ្ចឹង។ ហើយរាល់ថ្ងៃលោកពូធ្វើអីដែរ?

ហាតៈ ធ្វើជាងខាងសំណង់ វិហារ សាលាអី។

ដារ៉ាៈ អាហ្នឹងពូចេះពីខាងណាមកវិញ?

ហាតៈ អាហ្នឹងចេះនៅពីភ្នំពេញ។

ដារ៉ាៈ ពូទៅរៀន?

ហាតៈ បាទ! អាហ្នឹងខ្ញុំទៅធ្វើប្រឡូកជាក់ស្តែងនឹងគេនៅភ្នំពេញ

ដារ៉ាៈ អញ្ចឹងពូនិយាយពីជីវិតរបស់ ពូមានការសោកស្តាយទេ ដែលខំបំរើខ្មែរក្រហមពីណាពីណើមករហូតដល់រាល់ថ្ងៃហ្នឹង ហើយជីវភាពរបស់ពូរាល់ថ្ងៃហ្នឹងពូដូចជាគិតទៅមានការស្តាយក្រោយដែលបានបំរើខ្មែរក្រហមអញ្ចឹងណាពូ?

ហាតៈ បាទ! ខ្ញុំគិតថាវាស្តាយក្រោយនោះ វាស្តាយណាស់ណាទៅហើយ ខំតស៊ូ របួស ដាច់ ដៃ ដាច់ជើង ខំតស៊ូ។ ដូចខ្ញុំតែងនឹកឃើញថា បើតស៊ូដូចលោកហ៊ុន សែន ទៅមានអីដែលលោកហ៊ុន សែន កងពិសេសតែងទៅ គាត់នៅវេទនាជាងខ្ញុំទៀត។

ដារ៉ាៈ ពូដឹងដែរ?

ហាតៈ យ៉ាងម៉េចក៏មិនដឹងបើខ្ញុំទៅនោះពេលណាកន្លែងណា...អីខ្ញុំទៅហើយ។ ដែលកងពិសេសទៅនេះ ខ្ញុំស្រណោះខាងនោះជាងខាងនេះទៀត។

ដារ៉ាៈ ខាងហ៊ុន សែនហ្នឹង?

ហាតៈ បាទ! គេនៅនោះត្រាំ ខោអាវតែមួយចង្កេះដេកនៅតែខ្សែត្រៀមនឹងដីហ្នឹង។

ដារ៉ាៈ អញ្ចឹងហ៊ុន សែន ដូចថានៅជារបៀបជាមូលដ្ឋាននៅកន្លែងហ្នឹង?

ហាតៈ បាទ! ជាមូលដ្ឋានគេ ហើយពិបាកជាងខ្ញុំទៀត។

ដារ៉ាៈ អញ្ចឹងពូស្គាល់ហ៊ុន សែន ដែរ កាលនៅ?

ហាតៈ ខ្ញុំកាលនៅនោះណាខ្ញុំមិនដែលបានជួបគាត់ដែរទេ។ តែជួបដូចថា កូនទ័ពកូនចៅគាត់ទៅអញ្ចឹង ចុះតាមខ្សែត្រៀមដូចថាគេឲ្យមកពិនិត្យអញ្ចឹងណា ដូចពួកខ្ញុំដើរទៅស៊ើបការណ៍ជំនឹងថាវាមកត្រង់ណាត្រង់អី តែឲ្យខ្ញុំទៅធ្វើអី? ក៏សួរតាមរយៈអញ្ចឹងណាសួរតាមប្រធានកង ប្រធានអីអញ្ចឹងណា។ តាមលោក ហ៊ុន សែន គាត់ឡើងជាយោធាកងពល៥ហើយនោះ គាត់ឡើងធ្វើមេហើយហ្នឹង។

ដាវ៉ៈ អញ្ចឹងពេលដែលពូឡើងទៅវ៉ៃវៀតណាមហ្នឹង ដែលពូដឹងទៅតាម ហ៊ុន សែន?

ហាតៈ បាទ! ហ្នឹងឯង តាមខ្សែគ្រៀម ដូចថាខ្សែគ្រៀមយើងនៅដាក់ព័ទ្ធជុំវិញអញ្ចឹង ។

ដាវ៉ៈ អញ្ចឹងពេលហ្នឹង ហ៊ុន សែន ឡើងជាប្រធានពលហើយ ដែលគ្រៀមវ៉ៃជាមួយយួន?

ហាតៈ បាទ!

ដាវ៉ៈ កាលហ្នឹងនៅក្នុងឆ្នាំណា?

ហាតៈ ចុង ៧៨ ។

ដាវ៉ៈ កន្លែងនេះវាទាក់ទងនឹងប្រវត្តិសាស្ត្រវាច្បាស់លាស់អញ្ចឹងបានខ្ញុំសួរពូឲ្យបានច្បាស់លាស់ដែរពេលដែលពូចេញពីព្រលានយន្តហោះកំពង់ឆ្នាំង ហើយទៅវ៉ៃជាមួយវៀត ណាម ហើយវ៉ៃពូនៅកងពិសេស?

ហាតៈ បាទ!

ដាវ៉ៈ ហេតុអីបានជាពូទៅដឹងដល់កន្លែងលោកហ៊ុន សែន ហ្នឹង។ គាត់ហ៊ុន សែន កាលហ្នឹងធ្វើអីទៅ?

ហាតៈ គាត់ធ្វើខាងយោធា ខាងកងពលលេខ៥ ។

ដាវ៉ៈ ហេតុអីបានជាពូដឹងច្បាស់?

ហាតៈ ចុះបើគេដើរឲ្យដឹងដំនឹងថាឲ្យទៅកងពលលេខ៥ កងពលលេខ៤ គេប្រាប់យើងទៅ យើងទៅធ្វើការនៅកន្លែងនោះ តើសភាពការណ៍គេយ៉ាងម៉េច តើគេប្រើឲ្យយើងដាក់ មីន ឬក៏ដោះមីនយ៉ាងម៉េច យើងដាក់ផងយើងដោះផង ។

ដាវ៉ៈ ហើយដល់ពេលអញ្ចឹងទៅ លោកពូដឹថាហ៊ុន សែន ជាប្រធានកងពលលេខ៥?

ហាតៈ បាទ!

ដាវ៉ៈ ដែលគ្រៀមវ៉ៃខ្មែរក្រហម ឬក៏វ៉ៃវៀតណាម?

ហាតៈ គ្រៀមវ៉ៃវៀតណាម ។

ដាវ៉ៈ តែបើនិយាយអញ្ចឹងទៅហេតុអ្វីបានជាលោក ហ៊ុន សែន ទៅចូលវៀតណាម វ៉ៃខ្មែរក្រហមវិញបាន?

ហាតៈ អត់ដឹងដែរ ។ តែឮដំនឹងថាគេវ៉ៃ ខ្វាំងពេក គេចមិនរួចទេ ទាល់តែរត់ចេញទៅខាងនោះឯង ។ ខ្ញុំតាមរយៈដែលតាមនិរសាគាត់ គេនិយាយតពីគេដែរ ។ ពួនតែតាមព្រៃ អីទេ ដល់ហើយក៏បែកគំនិតទៅពឹងវៀតណាម ចូលទៅសារភាពនៅវៀតណាម មិនទាន់ជាពេញកម្លាំងថាពឹងទេណាបើតាមប្រវត្តិដែលមើលឃើញមកណា ។ តែឯងខ្មែរ

ក្រហមទៅពីងម៉េចទាន់ គម្រោងការណ៍តែម្នាក់ឯង គម្រោងការណ៍ទាល់តែមានគ្នា ច្រើន ។ ហើយគាត់វាអញ្ចេះដែង កាលនោះឯងដូចថា វាលែងដែទទេហើយ ប៉ុល ពត ហ្នឹង វ៉ៃសោ ភីមស្លាប់បាត់ទៅហើយ ថ្នាក់ភូមិភាគនោះ អាហ្នឹងបើតាមប្រវត្តិ ដែលខ្ញុំដឹង។ សោ ភីម មិនគណៈភូមិភាគ ហើយដល់ពួកខ្មែរក្រហមនោះចាប់ភូមិភាគ ចាប់បានមិនដឹងទេ រត់ទៅយួន ,ចាប់អត់បានទេ ថាគាត់បាញ់ខ្លួនគាត់ ។

ដារ៉ាៈ សោ ភីមហ្នឹង?

ហាតៈ បាទ! ប្រវត្តិនោះថាបាញ់ខ្លួនគាត់ ប៉ុន្តែខ្ញុំមិនបានឃើញទេ តែដំនឹងដែលខ្ញុំដឹងនៅនោះ ឯងឮថាបាញ់ខ្លួនឯងទេ។ ដល់ឯនេះភ័យមើលទៅថាសម្លាប់មេហើយ ខាងនេះដូចថា វ៉ៃ ដូចលោក ហ៊ុន សែន គាត់វ៉ៃមិនឈ្នះគេ ខ្លាចគេចាប់គគ្នាដែរ ដល់ហើយគាត់ គេចទៅ គេចទៅនៅស្រុកយួន ។

ដារ៉ាៈ អញ្ចឹងមុនពេលដែលហ៊ុន សែនទៅពីងវៀតណាមហ្នឹង គឺគាត់មានឋានៈជាប្រធានកង ពលលេខ៥?

ហាតៈ បាទ! ឆ្នាំប៉ុន្មានអីប៉ុន្មានអត់ដឹងទេ តែគេហៅកងពលលេខ៥ ខាងតាហ៊ុន សែននេះ ។

ដារ៉ាៈ អញ្ចឹងពូច្បាស់ក្នុងខ្លួនហើយដែលថាលោកហ៊ុន សែន មានឋានៈរហូតដល់ប្រធានកង ពលលេខ៥?

ហាតៈ បាទ! គាត់មិនមែនអ្នកតូចឯណា ។

ដារ៉ាៈ ពូដឹងតាមរយៈដូចថាមានការប្រជុំ?

ហាតៈ អត់ប្រជុំទេ គេប្រាប់ទេ ដូចថាគ្នាយើងគេប្រាប់ យើងសួរគេតទៅនៅកងណាកងណី អីអញ្ចឹងទៅ ។

ដារ៉ាៈ ហើយមេកើយអ្នកណាអ្នកណីអញ្ចឹង?

ហាតៈ បាទ! ឈ្មោះនេះឈ្មោះនោះទៅ ។ តែជួបជាមួយគាត់មិនស្គាល់ផងមុនដំបូងមិនដឹង អ្នកណាផង ទើបតែស្គាល់សព្វថ្ងៃនេះ ។

យិនៈ ខ្ញុំសូមសួរមួយទៀត តា ហេង សំរិន ពីដើមថាកាន់កងពលដែរ តើមានស្គាល់គាត់ទេ ពេលទៅហ្នឹង?

ហាតៈ អត់ស្គាល់ផង ។

ដារ៉ាៈ ស្គាល់តែ ហ៊ុន សែនទេ?

ហាតៈ បាទ! ស្គាល់តែ ហ៊ុន សែន ។ ខ្ញុំពីដើមតែងឮគេហៅ កូនចៅគាត់នៅតាមខ្សែ ត្រៀម ។

ដារ៉ាៈ ហៅឈ្មោះអញ្ចឹងម៉ង ឬក៏ហៅយ៉ាងម៉េច?

ហាគៈ ហៅអញ្ចឹងឯងនេះតែម្តង ។

ឃិនៈ អត់មានឈ្មោះអីដូរអីទេ?

ហាគៈ អត់មានដូរទេ ។

ដារ៉ាៈ ហៅ ហ៊ុន សែន គឺ ហ៊ុន សែនអញ្ចឹងម៉ង?

ហាគៈ បាទ! ពុស្សូរគេហៅអញ្ចឹង ។

ដារ៉ាៈ ពូរាល់ថ្ងៃហ្នឹងមានបានដឹងរឿងរ៉ាវនៃការចចារគ្នា រវាងរដ្ឋាភិបាលជាមួយអង្គការសហប្រជាជាតិ ជាមួយរដ្ឋាភិបាលបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេពូ?

ហាគៈ ពុដែរ ប៉ុន្តែគែកាត់ហ្នឹងមិនដឹងទៅណាទេ ។ ខ្ញុំក៏មិនទាន់ដឹងគេកាត់ទោសខ្មែរក្រហមហ្នឹងយ៉ាងម៉េចអីយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ ។

ដារ៉ាៈ អញ្ចឹងពូយល់យ៉ាម៉េចដែរ បើសិនជាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

ហាគៈ ខ្ញុំយល់យ៉ាងម៉េច ក៏ស្រេចតែអ្នកដឹកនាំក្រោយនេះ កាត់យ៉ាងម៉េចក៏កាត់ទៅ ។ ខ្ញុំនោះវាថោកតែខ្លួនឯងហើយ ឥឡូវនៅតែប្រជាជនគាត់កាត់ ឲ្យស្លាប់ៗទៅ ឲ្យម៉េច ក៏ម៉េចទៅទោសហ្នឹងក៏ខ្ញុំវាពិបាកនិយាយដែរ ។

ដារ៉ាៈ អត់ទេខ្ញុំសួរនេះមិនមែនសំដៅថាកាត់ទោសពូទេណា ។

ហាគៈ ទេ ខ្ញុំវានិយាយក៏យល់ដឹងច្បាស់អញ្ចឹងដែរហើយ ធម្មតាគេកាត់ទោសខ្មែរក្រហមហ្នឹងវាមានឋានៈច្បាស់តាមក្នុងការអន្តរជាតិ ។

ដារ៉ាៈ ព្រោះក៏ធ្លាប់បម្រើឲ្យខ្មែរក្រហមនោះដែរ ហើយបើសិនជាមានកាត់ទោសមេខ្មែរក្រហមទៅ ធ្វើឲ្យមានការបែកបាក់សាមគ្គីភាព ឬក៏យ៉ាងម៉េច តាមពូយល់?

ហាគៈ ខ្ញុំដូចយល់មិនទាន់ផង ។

ដារ៉ាៈ ឬក៏ថាមានការកាត់ទោសទៅ វានាំឲ្យមានសង្រ្គាមស៊ីវិល?

ហាគៈ ខ្ញុំបើតាមថាកាត់ផ្តាច់ចោល ក៏វាគ្មានទោសអីដែរ នេះតាមគំនិតខ្ញុំណា ។

ដារ៉ាៈ គ្មានទោសហ្នឹងពូចង់សំដៅថា បើសិនជាកាត់ទៅគ្មានបញ្ហាអីដែរ?

ហាគៈ បាទ! គ្មានបញ្ហាទេ ។ បើថាប្រទេសក្រៅអីយ៉ាងម៉េចមិនដឹងទេណា បើថានៅប្រទេសខ្មែរគេកំពង់ស្អប់ផង អញ្ចឹងបានជាខ្ញុំថាវាទៅមិនរួច ។

ដារ៉ាៈ អញ្ចឹងការរៀបរាប់របស់ពូប្រាប់ខ្ញុំពីខាងដើមមកហ្នឹង គឺសុទ្ធតែជាការចងចាំរបស់ពូ?

ហាគៈ បាទ!

ដារ៉ាៈ ហើយ ខ្ញុំក៏គ្មានការបង្ខិតបង្ខំអីឲ្យពូឆ្លើយទេ ។ គ្រាន់តែខ្ញុំសួរតាមលំដាប់លំដោយ ។ ហើយពូគិតថា ការដែលពូនិយាយចេញមកទាំងអស់ហ្នឹង ជាការពូចងចាំច្បាស់លាស់ ឬមានពេលសួលើក្រោយទៅ ពូអាចឆ្លើយថា ខ្ញុំចេះតែឆ្លើយៗទៅ ។ ម៉េចដែរពូ?

ហាគៈ អានេះវាអញ្ចេះ វាសួរទៅ ជួនកាលដូចថា សួរពីដំនើរពីមុនមក ដូចសួរថា ពីកាលដែលខ្ញុំនេះគេចាប់ខ្ញុំទៅដាប់គុកដាប់អីហ្នឹងណាស់តហូរហែទៅ អាហ្នឹងអញ្ចឹងទេ ។ ដល់គេចាប់ដូចថា ខ្ញុំចាប់ធ្វើទាហានធ្វើខ្មែរក្រហម គេយកទៅរៀននៅល្អុងអញ្ចេះទៅ ខ្ញុំចាប់និយាយត្រង់ហ្នឹងទៅរហូតទៅ ។

យិនៈ អានេះវាផ្តោតទៅលើប្រវត្តិជាក់ស្តែង ហើយនិងការចងចាំ?

ហាគៈ បាទ! និយាយទៅ ជួនការវាផុតគ្នានេះណា ដែលថាខ្ញុំទៅនេះទៅដល់ថ្នល់ទទឹង កំពង់ថ្ម កំពង់អីហ្នឹងណា ។ មានគេសួរខ្ញុំដែរពីរឿងធ្វើដំនើរពីរឿងវេទនានោះ និយាយមួយយប់មិនអស់ផង ។

ដារ៉ាៈ នៅក្នុងពូអីប្រជាជន ដឹងថាពូធ្វើខ្មែរក្រហមពីមុនដែរ?

ហាគៈ បាទ! ដឹងទាំងអស់ ហើយចង់ដឹងប្រវត្តិថា ស្រួលពិបាក អីអញ្ចេះៗ ។

ដារ៉ាៈ អញ្ចឹងមានប្រជាជនអីគាត់មានសួរនាំពូអីដែរ?

ហាគៈ សួរនាំដែរ ។

ដារ៉ាៈ អញ្ចឹងពូនិយាយប្រាប់គេដែរ?

ហាគៈ និយាយប្រាប់ ។

ដារ៉ាៈ ពូអត់ខ្លាចគេថា ធ្លាប់ធ្វើខ្មែរក្រហមអីទេ?

ហាគៈ អត់ខ្លាចទេ ។

ដារ៉ាៈ ហើយអ្នកស្រុកអ្នកភូមិរាប់អានពូធម្មតាទេ?

ហាគៈ បាទ! អ្នកស្រុកអ្នកភូមិវាទូទៅហើយ ភ្លេចខ្មែរក្រហមអស់រលីងហើយ ។

ដារ៉ាៈ អញ្ចឹងគ្រួសារពូ កូនពូអីមានដឹងពីបញ្ហាហ្នឹងទេពូ?

ហាគៈ កូនខ្ញុំវានៅតូចៗដែរ ដឹងអាមួយវាបងនោះ តែទើបឆ្នាំ៨១ ៨២ នេះ បានមានកូន បានវាដឹង វាអត់មានដឹងរបបហ្នឹងទេ ទាល់តែយើងនិយាយប្រាប់ទៅបានដឹង ។

ដារ៉ាៈ អញ្ចឹងធ្លាប់និយាយប្រាប់កូនចៅដែរ?

ហាគៈ និយាយប្រាប់ដែរ អាធំៗ ដូចថាវា ខ្ជិល ច្រអូស វាមិនសូវធ្វើការងារ ។

ដារ៉ាៈ ហើយចុះគ្រួសារពូ?

ហាតៈ  គ្រួសារខ្ញុំថឺមិនដឹង ដឹងប្រវត្តិ ។

ដារ៉ាៈ  អញ្ចឹងគាត់អត់មានស្អប់ខ្មែរមពូទេ?

ហាតៈ  អត់មានអីទេ ។ គ្រួសារខ្ញុំអ្នកភ្នំពេញ ។

ដារ៉ាៈ  អ្នកភ្នំពេញ?

ហាតៈ  អ្នកភ្នំពេញ ។

ឃិនៈ  ការឆ្នាំណា?

ហាតៈ  ការ៧៩ ។

ដារ៉ាៈ  មកនៅនេះ គ្រួសារមកដែរ?

ហាតៈ  មកនៅ ។

ដារ៉ាៈ  នៅជាមួយពូហ្នឹងរាល់ថ្ងៃ?

ហាតៈ  រាល់ថ្ងៃនៅ ។

ដារ៉ាៈ  កូនចៅគេនៅម្តុំណា?

ហាតៈ  បើពីមុននៅគីឡូលេខ៦ ។

ដារ៉ាៈ  ហើយជួបគ្នា តាមរយៈណា ការឆ្នាំណា?

ហាតៈ  កាលជំនាន់ខ្ញុំធ្វើការឲ្យវៀតណាមនេះណា ។

ដារ៉ាៈ  រាល់ថ្ងៃជីវភាពរបស់ពូ វាគ្រប់គ្រាន់ឬក៏?

ហាតៈ  ខ្ញុំស្ថានភាពគ្រួសារវាខ្វះខាតច្រើន ។

ដារ៉ាៈ  ប៉ុន្តែពូចេះសំនង់ដែរ?

ហាតៈ  បាទ! ចេះបានបន្តិចគ្រាន់បានអង្ករហូប ។

ដារ៉ាៈ  អញ្ចឹងខ្ញុំអរគុណពូច្រើនដែលបានជួយផ្តល់ពត៌មាន ។

**ចប់**